Reçu le 30 Mai 1.949

# ព្រះរាជាណាចក្រ កម្ពុជា

INDOCHINE FRANÇAISE
DÉPÔT LÉGAL

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ១ លេខ ២

ខែតុលា ព.ស. ២៤៩២

Octobre

ឆ្នាំសិក្សា ១៩៤៩-១៩៥០

ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ


ពាក្យប្រែ បារាំង - ខ្មែរ ........................................ ៣

វេយ្យាករណ៍ សង្ខេប ........................................ ៥

វិធីរៀនជាបឋម ........................................ ៧

វេយ្យាករណ៍ វណ្ណយុត្ត ........................................ ១៣

ឧត្តមដ្ឋាន ........................................ ១៥

មធ្យមដ្ឋានទី ២ និងមធ្យមដ្ឋានទី ១ ........................................ ១៧-២០

អាទិកដ្ឋាន ........................................ ២៣

បរិវច្ឆណដ្ឋាន ........................................ ៣១

មធ្យមដ្ឋានទី ១ នព្វន្ត មធ្យមដ្ឋានទី ១ ទី ២ រង្វាស់រង្វាល់ ........... ៣៦-៤៣-៤៦

អាទិកដ្ឋាន - នព្វន្ត ........................................ ៥០

បរិវច្ឆណដ្ឋាន ........................................ ៥២

កុមារដ្ឋាន-នព្វន្ត និងកុមារដ្ឋានរង្វាស់រង្វាល់ ........................................ ៥៦ - ៥៨

អាទិកដ្ឋាន - វត្ថុស្ហាគ្យាបេន ........................................ ៥៩

បរិវច្ឆណដ្ឋាន ........................................ ៦៣

លោកនិតិ -សម្រាប់គ្រប់ថ្នាក់ ........................................ ៦៥

មេសូត្ររត់មាត់ ( គ្រប់ថ្នាក់ ) ........................................ ៧១-៧៦

# MOTS A TRADUIRE

| | |
|---|---|
| Bimensuel . . . . . . . . . . . : | អឌ្ឍមាស |
| Mensuel . . . . . . . . . . . . : | អនុមាស |
| Bihebdomadaire . . . . . . . . : | ទ្វិះសប្តាហ |
| Revue de l'Instituteur khmer . : | ទស្សនាវដ្ដីសម្រាប់គ្រូបង្រៀន |
| Partisan . . . . . . . . . . . . : | បក្សព័ន្ធ |
| Règle . . . . . . . . . . . . . : | ក្បួនខ្នាត |
| Règlement . . . . . . . . . . . : | បទបញ្ញា |
| Règlementation . . . . . . . . : | ការតាំងបទបញ្ញា |
| Document . . . . . . . . . . . : | ឯកសារ |
| Archives . . . . . . . . . . . . : | ទីទុកឯកសារ |
| Archiviste . . . . . . . . . . . : | អ្នកទុកឯកសារ |
| Titre . . . . . . . . . . . . . . : | ឋានន្តរ |
| Grade . . . . . . . . . . . . . : | ឋានន្តរស័ក្តិ, បណ្តាស័ក្តិ |
| Classe . . . . . . . . . . . . . : | ថ្នាក់ |
| Cadre . . . . . . . . . . . . . : | ក្របខ័ណ្ឌ |
| Attaché militaire . . . . . . . . : | សេនានុព័ន្ធ |
| Directeur des affaires, politiques, administratives, . . . . . | នាយកនៃកិច្ចការនយោបាយ, រដ្ឋបាល, |
| Sociales et Culturelles . . . . : | សង្គម និងវប្បធម៌ |
| Salle des conférences . . . . . : | សាលសន្និសីទ |
| Directeur des affaires économiques et financières . . . . : | នាយកនៃកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| Chef du Service Administratif . : | នាយក្រុមរដ្ឋបាល |
| Directeur des Bureaux Administratifs . . . . . . . . . : | នាយកប៊ុយរ៉ូរដ្ឋបាល |
| Inspection en Chef de l'Enseignement primaire . . . . . . : | មន្ទីរអធិការនាយកបឋមសិក្សា |

| | |
|---|---|
| Service d'ordre . . . . . . . : | ក្រុមរបៀប |
| Bureau de personnel . . . . . : | ប៊ុយរ៉ូបុគ្គលិក |
| Réunions . . . . . . . . . . . : | សន្និបាត |
| Bibliothèque . . . . . . . . . . : | បណ្ណាល័យ |
| Etablisements scolaires . . . . : | គ្រឹះស្ថានសិក្សា |
| Bourse . . . . . . . . . . . . : | អាហារូបករណ៍ |
| Secours scolaires . . . . . . . : | ជំនួយសិក្សា |
| Secrétariat . . . . . . . . . . . : | លេខាធិការដ្ឋាន |
| Comptabilité . . . . . . . . . . : | បញ្ជី |
| Office des Etudiants Cambodgiens . . . . . . . . . . : | មន្ទីរសង្គហៈនិស្សិតខ្មែរ |
| Propagande, publication et organisation sociale scolaire . : | ឃោសនា, ការផ្សាយនិងការរៀបចំសង្គមសិក្សា |
| Service de l'Immigration . . . : | ក្រុមជនចូលស្រុក |
| Inspection . . . . . . . . . . . : | អធិការដ្ឋាន |
| Cantonnement . . . . . . . . . : | ទ័ណ្ឌ |
| Division . . . . . . . . . . . . : | ផ្នែក |
| Triage . . . . . . . . . . . . . : | ការស្រាល់ជ្រើស |
| Directeur . . . . . . . . . . . . : | ចាងហ្វាង |
| Surveillant général . . . . . . : | អគ្គានុរក្ស |
| Surveillant . . . . . . . . . . . : | អនុរក្ស |
| Economat . . . . . . . . . . . : | ទីអ្នកផ្គត់ផ្គង់ |
| Econome . . . . . . . . . . . . : | អ្នកផ្គត់ផ្គង់ |
| Lingère . . . . . . . . . . . . . : | ធោរីការ, បុំ. m. ធោរីក |
| Lingerie . . . . . . . . . . . . : | ធោរីនដ្ឋាន |
| Linge . . . . . . . . . . . . . : | ធោរីនពស្ត្រ |
| Dortoir . . . . . . . . . . . . . : | សយនដ្ឋាន |
| Douche . . . . . . . . . . . . . : | នហានដ្ឋាន, កន្លែងងូត |

Réfectoire . . . . . . . . . . . . . : ភោជនដ្ឋាន

Cuisine . . . . . . . . . . . . . : ផ្ទះបាយ

Atelier . . . . . . . . . . . . . : រោងជាង

Salle de consigne . . . . . . . . : សាលទណ្ឌកម្ម

Classe de 6 ᵉᵐᵉ Noderne A . . : ថ្នាក់ទី ៦ ទំនើប ក

Cours Supérieur spécial . . . . . : ឧត្តមដ្ឋានពិសេស

---

# សាលាបាឡីរងវត្តឧណ្ណាលោម

*ថ្ងៃ១៨ សីហា គ.ស. ១៩៤៨ ព.ស. ២៤៩១*

## ខេមរវេយ្យាករណ៍ សង្ខេប

### វិភត្តិនាម " Désinence "

| | | |
|---|---|---|
| ១ | បឋមា | Nominatif |
| ២ | ទុតិយា | Accusatif |
| ៣ | តតិយា | Instrumental |
| ៤ | ចតុត្ថី | Datif |
| ៥ | បញ្ចមី | Ablatif |
| ៦ | ឆដ្ឋី | Génitif |
| ៧ | សត្តមី | Locatif |
| ៨ | អាលបនៈ | Vocatif |

បឋមា

១.– នាមនាម ឬ គុណនាម ដែលប្រើជាបទប្រធាន (Sujet) ហៅថាបឋមាវិភត្តិ ប្រើពាក្យជាអាយតនិបាតថា “រី,រីឯ” ឬមិនបាច់ប្រើពាក្យនេះក៏បាន សំគាល់ត្រឹមតែបទជាប្រធានប៉ុណ្ណោះ

ឧទាហរណ៍ : យោ មាតាបិតុបដ្ឋាកោ រីជនណាជាអ្នកបំរើមាតាបិតា, កុំថាឡើយមនុស្សផងគ្នា ទោះទាំងទេវតាក៏គង់លើកសរសើរជននោះដែរ ។

ពាក្យ “រី” ឬ “រីឯ” ច្រើនប្រើក្នុងកាព្យឃ្លោង ជាងសេចក្ដីរាយ សូម្បីកិរិយាសព្ទ ក៏អាចប្រើពាក្យនេះផ្សំជាមួយផងបានដែរ, ឧ. រីទោសផ្ទុយនឹងគុណ រីឯបុណ្យផ្ទុយនឹងបាប រីប្រែផ្ទុយនឹងសាប រីឯលាភផ្ទុយនឹងឃ្មែត ។ល។ រីមូលពឹងក្រឡឹង រីឯត្រង់ពឹងបន្ទាត់ ជដែកពឹងប្ដីមាត់ រីការណ៍ភ្ជាត់ពឹងប្រយ័ត្ន

ទុតិយា

២.– ទុតិយាវិភត្តិ ប្រើពាក្យជាអាយតនិបាត ៥ យ៉ាង :

ក) “នូវ” ហៅថា អវុត្តកម្ម, ឧ. គេ,យើញ នូវ រូបដោយភ្នែក ពាក្យ “នូវ” ឬ “នូវអស់” អាចប្រើជាជំនួសពាក្យ

"នឹង, នឹងអស់" (ទូន្ទ:) ផងក៏បានខ្លះ, ។ ព្រះរាជឱង្ការនូវ ព្រះបន្ទូលស្បូរសីហនាទ ៗ នៅវេលាសាយណ្ហសម័យម៉ោង ១៦ អស់លោករដ្ឋមន្ត្រីនឹងមន្ត្រីធំតូច នូវអស់ គហបតីនានាព្រមទាំងជនានុជន បានមកប្រជុំគ្នាដាងកប្បហេរក្នុងទីនោះ ៗ

---

## សាលាបាឡីវត្តឧណ្ណាលោម

*នៅថ្ងៃទី ៩ សីហា គ.ស. ១៩៤៨ (ព.ស. ២៤៩១)*

## វិធីរៀនដំបូង

*មេរៀនទី ១* — អធិប្បាយអំពីសំឡេងភាសាបាឡី ឃោស នឹងអឃោសៈ ឬឃោសាឃោសៈ ។

ឃោសៈ — មានសំឡេងគឹកកង, ភាសាបារាំងហៅ (Sonore)

អឃោសៈ — គ្មានសំឡេងគឹកកង, បារាំងហៅ (Sourd)

ឃោសាឃោសៈ — គឺឃោសៈនឹងអឃោសៈរួមគ្នា ឯភាសាបាឡីត្រូវលុប "អះ" មួយចោល ហើយដាក់ស្រៈ

"ា" ត្រង់តួ "ស" ជា "សា" ទើប
មើលថា ឃោសាឃោសៈ តែសេចក្ដីត្រូវគ្នា
នឹងឃោសៈអឃោសៈនោះដែរ ។

ដូចគ្នានឹងភាសាបារាំងសែស «Le enfant»
លុបស្រៈ (Voyelle) មួយចោល គេមើលថា
"L'enfant"

---

*មេរៀនទី ២* – ចំនួនអក្ខរៈ ជាឃោសៈ នឹងអឃោសៈ

ឃោសៈ – មាន ២១ តួ គឃង-ជឈញ-ឌឍណ-ទធន-ពភម-យរលវហឡ ។

អឃោស – មាន ១១ តួ កខ-ចឆ-ដឋ-តថ-បផ-ស ។

---

*មេរៀនទី ៣* – ចំនួនអក្ខរៈ ជាសិថិលនឹងធនិត

សិថិល – សំឡេងធូរឬស្រាល (Inaspiré) មាន ១០ តួ: កគ-ចជ-ដឌ-តទ-បព ។

ធនិត – សំឡេងតឹង ឬ ខ្លាំង (Aspiré) មាន ១០ តួ: ខឃ-ឆឈ-ឋឍ-ថធ-ផភ ។

---

មេរៀនទី៨– បើបង់រក ធនិត ត្រូវយក សិថិល មកផ្ញើជើង ហ

ដូចជា– ក ផ្ញើជើង ហ ជា ក្ហ គឺ ខ k+h) kh

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| គ | " | ហ | " | គ្ហ | " | ឃ | g+h) gh | |
| ច | " | ហ | " | ច្ហ | " | ឆ | c+h) ch | (en pali) |
| ជ | " | ហ | " | ជ្ហ | " | ឈ | j+h) jh | (en pali) |
| ដ | " | ហ | " | ដ្ហ | " | ឋ | t+h) th | " |
| ឌ | " | ហ | " | ឌ្ហ | " | ឍ | d+h) dh | " |
| ត | " | ហ | " | ត្ហ | " | ថ | t+h) th | " |
| ទ | " | ហ | " | ទ្ហ | " | ធ | d+h) dh | " |
| ប | " | ហ | " | ប្ហ | " | ផ | p+h) ph | " |
| ព | " | ហ | " | ព្ហ | " | ភ | b+h) bh | " |

(ចូរមើលសៀវភៅកច្ចាយនូបត្ថម្ភក: បែបរៀនភាសាបាលីភាគទី១)

---

មេរៀនទី៩– អក្សរបំបែក ពួកឃោសៈ

គ គា គិ គី ។ល។ គុ គំ គាំ គះ

កុំថា គុម គាំ គ៉ាម់ ព្រោះតួ (គ៉ាម់) នេះ ជាពាក្យខ្មែរ

សម័យពីដើម ឯសម័យឥឡូវក៏នៅប្រើខ្លះដែរ ខាងពួកខ្មែរនៅទីប្រទល់ដែន ។ ចំណែកខ្មែរសម័យឥឡូវ ដែលនៅក្នុងក្រុង ឬនៅក្នុងខេត្តនានា គេមិនសូវប្រើ; ប្រើនិយាយថា: ជួយគាំពារ ឬគាំទ្រចិត្ត គំនុំ-គួរគំនួរ-គុំគួន: លោកសង្ឃ ឃុំចីពរ-ឃុំសេះ-ឃ្លាំមើលមនុស្សល្ងូប: ក្តៅងំ-បាយងំ; ដើរមួយជុំ ល័ខជុំកន្លង់-ជុំជី-មនុស្សពេញជំទង់-លោកជំទប់-បងជំទាញ-លោកជំទាវ-ខ្មៅជាំ-មុខជាំជោកជាំ-ព្រៃជាំ; បុកអំបិលញាំៗ-ទំពាញាំៗ-ញាំសាឡាត់-ញាំត្រសក់-ស្វាយទុំ-បាស់ទុំ-ក្អែកទំលើទ្រនំ-មានទំងន់-ធ្វើខុសទំនងទំនុកបំរុងមាំទាំ-ថែទាំ-ជុំក្រអូប-ដំរីធំ-ធំបងឪ-ឪពុកធំ-នំអាកោនាំរកស៊ី-ពុំនាំពា-ពុំសូវល្អ-ពំនៀរ-ពាំពាក្យពាំសំដី-ព្រំផ្ទះ-ព្រំប្រទល់-ក្រាលព្រំ-ទឹកកើតព្រំ; ភ្នំភ្លើង; ផ្លែម្រុំ-យំយែក-រុំខ្សែ-រំកាប់ឈើ-ប្រែងរាំ-ឈើរលំ-ឈូសឈើលំៗ-លំនៅ-លំកូនទាំងបួននាក់នោះ ។

---

## មេរៀនទី ៦ — ពន្យល់របៀបតែងប្រយោគ

(ពាក្យស្រង់យកពីសារពត៌មានកម្ពុជា)

## មាននាវាមួយ មកពីហៃហ្វុង

*បានមកដល់កំពង់ភ្នំពេញហើយ*

---

ភ្នំពេញ – កាលពីម្សិលម្ង៉ៃ នៅវេលាម៉ោង ១៥ និង ៣០ នាទី មាននាវាមួយដឹកទំនិញ ដែលចេញមកពីក្រុងហៃហ្វុងឈ្មោះ“គូលី” បានមកដល់កំពង់ផែភ្នំពេញ នេះគឺជាលើកដំបូងបង្អស់ហើយដែលមាននាវាដឹកទំនិញផ្ដោះត្រង់ពីក្រុងហៃហ្វុងមកក្រុងភ្នំពេញតែម្ដង ។ នាវានោះមានបំណុះ ៣៥០ តោន ពីរជាន់ហើយល្បឿន ២១ គ.ម. ៦០០ ក្នុងមួយម៉ោង ។ នាវានេះនឹងរៀបដំណើរទៅប្រទេសតុងកឹងវិញដោយផ្ទុកយកឈើទៅផង ។ ការណ៍នេះគេទុកជាជំហានជាបឋមនៃការប្រស្រ័យ នៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជារវាងនានាប្រទេសដែលនៅជិតខាងត្រង់តែម្ដង ដោយមិនចាំបាច់ចូលកំពង់ព្រៃនគរឡើយ ។

---

## សេចក្ដីកែប្រយោគខាងលើ

មាននាវាពីរជាន់ឈ្មោះ“គូលី” មានបំណុះ៣៥០តោន មានល្បឿន២១ គ.ម. ៦០០ក្នុងមួយម៉ោង បានចេញពីក្រុងហៃហ្វុងផ្ដោះ

ត្រង់មកប្រទេសកម្ពុជាតែម្តង បានមកដល់កំពង់ផែក្រុងភ្នំពេញពីម្សិលម៉្ងៃនៅវេលាម៉ោង១៥និង ៣០ នាទី ។ នាវានោះនឹងចេញទៅប្រទេសតុងកឹងវិញ ដោយផ្ទុកយកឈើទៅផង ។

នេះជាបឋមគមនាគមន៍នៃការប្រស្រ័យខាងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជារវាងនានាប្រទេសជិតខាង ដោយមិនបាច់ចូលកំពង់ព្រៃនគរឡើយ ។

(ប្រយោគនេះ ជាសេចក្តីកែរបស់ព្រះតេជព្រះគុណសង្ឃនាយក ជ. ណ.)

## វេយ្យាករណ៍

### វណ្ណយុត្ត

សញ្ញាទាំងឡាយដែលគេបន្ថែមលើអក្សរ ដើម្បីសំអៀងសព្ទពីសព្ទធម្មតា ឬធ្វើលក្ខណៈសេចក្ដីឲ្យមានសង្កាត់ច្បាស់លាស់ ហៅវណ្ណយុត្តឬយុត្តិ ។ វណ្ណយុត្តិទាំងឡាយ គឺៈស្បៀសញ្ញាឬបន្តក់ ( ' ): មូសិកទន្ត ( " ); ត្រីសព្ទ ( ˜ ); សំយោគសញ្ញា ( ˊ ); របាទ ( ៌ ); ទណ្ឌឃាត ( ៍ ) អស្តា ( ៏ ); វិសៈជនី ( ះ ); យុគលពិន្ទុ ( : ); ល្បះ ( ។ ); ល្បះចប់ ( ៕ ); កាកបាទ ( + ) លៈ ( ។ល។ ); វង់ក្រចក ( ); អព្ទូរ ( « » ); ទោ ( ៗ ); ឬហៅអាមេណ្ឌិតសញ្ញា: កុក្កុដនេត្រ ឬភ្នែកមាន់ ( ៙ ); គោមូត្រ ( ៚— ); រ៉ាត់ ( { ) វុដ្ឋសញ្ញា ( – ); មច្ឆណ្ឌសញ្ញា ឬពងត្រី ( ...... ) ។

សញ្ញាមូសិកទន្តផ្ទេរសព្ទអក្សរឃោសៈក្នុងព្យញ្ជនៈ ឲ្យទៅជាអក្សរអឃោសៈ ឯត្រីសព្ទធ្វើសព្ទអក្សរអឃោសៈជាឃោសៈ ។ ប៉ុន្តែនឹងផ្លែងសព្ទដោយវណ្ណយុត្តិនេះ គេធ្វើបានតែលើអក្សរទ្វិសព្ទ ឬត្រៃសព្ទ ។ អក្សរទ្វិសព្ទទាំងឡាយ គឺ ង ញ ណ ន ប ម យ រ ល វ ស ហ អ ។ អក្សរ ប ជាត្រៃសព្ទ ។ ក្នុងពួកព្យញ្ជនៈបន្ថែម គេមានបទប្រើមូសិកទន្តនឹងត្រីសព្ទជាពីរយ៉ាង នោះកាលណាពាក្យកើតឡើងពីព្យញ្ជនៈបន្ថែមនៅតែឯង ទូបុះជាដើ ព្យាង្គ គេដាក់មូសិកទន្ត ឬត្រីសព្ទពីលើអក្សរ ផ្ទួនដាក់ពីក្រោមអក្សរ ឧបមាដូចពាក្យ ប៊ុន, ប៉ុន្តែ, ញ៉ាម, ង៉ែត, ហ៊ាន, ស៊ាម, ប៊ិន, ញ៉ាំ, ម៉ឺ, ស៊ី, អ៊ឹម.... ។ បើកាលណាមានសព្ទរបស់ព្យាង្គខាងដើមនាំមុខ ឬពាក្យចេញមកពីបាលីឬសំស្ក្រឹត គេមិនប្រើវណ្ណយុត្តឡើយ ឧបមាដូចពាក្យ កង្វល់ (កង់-វល់), បន្ទាយ (បន់-ឡាយ), កំរ ឬ កម្រ (កំ-រ៉), គ្រឹហា (គ្រិ-ហ៊ា), ទាហាន (ទា-ហ៊ាន), វិហារ (វិ-ហ៊ារ), សេនា (សេ-ណា); សញ្ញា (សាញ់-ញ៉ា), វិញ្ញាណ (វិញ-ញាន) ។ ក្នុងពួកព្យញ្ជនៈផ្សំ គេក៏មិនប្រើវណ្ណយុត្តដែរ ។ ជើងអក្សរទ្វិសព្ទផ្លាស់សព្ទតាមតួលើ គឺថាបើតួលើជាអឃោសៈឬឃោសៈ ជើងដែលផ្ញើផ្លាស់តាមជរាប ដូច = ខ្ល (ខ-ល៉), ឃ្ល (ឃ-ល) ទ្រ (ទ-រ), ថ្វ (ថ-វ៉).... លើរតែជើងអក្សរឯកសព្ទដែលមិនផ្លាស់សព្ទតាមតួលើឡើយ ស្ក (ស-ក), ខ្ទ (ខ-ទ).....

**បន្តក់**.— បន្តក់ប្រើលើពាក្យដែលជារស្សសព្ទតិចតួច ហើយដែលកើតពីស្រៈ អ នឹងស្រៈអា បក់-ចាត់-ទាត់-លក់ ··· ។ បន្តក់មិនប្រើលើពាក្យបាលីឬសំស្ក្រឹតឡើយ ឬមិនប្រើលើតួប្រកបដែលជាអក្សរ ខគឃ ឆជឈ ឋឌឍណ ថទធផភយរឡ ។

**សំយោគសញ្ញា**.— សំយោគសញ្ញាសំអៀងសព្ទបាលីឬសំស្ក្រឹតដែលប្រើក្នុងភាសាខ្មែរ= ក្ស័យ, ភ័យ, ជ័យ, ព័ន្ធ (ពាន់), សម្បត្តិ ឬ សម្ប័ទ ···· ។ គេប្រើក្នុងពាក្យខ្មែរខ្លះដែល កាលណាពាក្យនោះមិនពេញលេញជាស្រៈ អ ឬស្រៈ អា ហើយមានអក្សរ រ ជាប្រកប = ទំព័រ, ញ័រ, សង្ស័រ, ង័រ ····· ។

ទណ្ឌឃាត ឬបដិសេធ សំឡាប់បង់អក្សរលើសពីអាន = បោទក៍, រតន៍ ····· របាទជំនួស តួតម្រួតឬអក្សរដែលនៅក្នុងចន្លោះ = ធម៌, មារ៌ា, កក៌ដ, ទូត៌ ··· · ជាធម្មតា របាទប្រើនៅចុងពាក្យ នឹងពាក្យក្នុងចន្លោះ = គេស្ដាប់ធម៌, ធ្វើធម្មទាន, ទូរគត ។

អស្ដាដាក់លើអក្សរ ក នឹង ដ កាលណាពាក្យនោះជានិបាត = ក៏ដោយ, ដ៏មានបុណ្យ ។

---

**ពាក្យចោទសួរ**.— ១)— ព្យញ្ជនៈមានអក្សរអ្វីខ្លះ? — អក្សរប៉ុន្មាន? ។ ២)— ព្យញ្ជនៈមានប៉ុន្មានយ៉ាង? (ព្យញ្ជនៈធម្មតា, ព្យញ្ជនៈបន្ថែម, ព្យញ្ជនៈផ្សំ) ។ ៣)— ព្យញ្ជនៈបន្ថែមជាអក្សរយ៉ាងដូចម្ដេច? — មូសិកទន្តជាអ្វី? — ។ ៤)— សញ្ញាទាំងឡាយមានឈ្មោះអ្វីខ្លះ? រូបរាងដូចម្ដេច? ។ ៥)— ចូរអធិប្បាយវិធីប្រើមូសិកទន្តនឹងត្រីសព្ទ ។ ៦)— បន្តក់ប្រើលើពាក្យដែលកើតពីស្រៈអ្វីខ្លះ? — ដាក់លើតួប្រកបដែលជាអក្សរអ្វីខ្លះ? ។ ៧)— ប្រើការដូចម្ដេច = សំយោគសញ្ញា, របាទ, បដិសេធឬទណ្ឌឃាត, អស្ដា ។

**សេចក្ដីបំណាំ**.— ក) កុំប្រើទណ្ឌឃាតលើជើងអក្សរដែលគេប្រទះរឿយ ៗ លើជើង ឃ, ស, ប ។ — ខ) កុំយកជើងអក្សរជាតួប្រកប

## ឧត្តមដ្ឋាន

### *សាលាលិសេ ឬ វិទ្យាល័យស៊ីសុវត្ថិ*

បើអ្នកៈទៅតាមផ្លូវឌូដារ្ដដឺឡាគ្រេពីងជើងទៅត្បូង អ្នកនឹងឃើញជាស្ដាំអ្នក ទីស្ថានមួយធំទូលាយ មានកំពែងលំហោកព័ទ្ធពីមុខ មានផ្ទះខ្ពស់ ៗ ធំ ៗ វែង ៗ នឹងផ្ទះនៅមុំកំពែងឆ្វេងស្ដាំធំល្មមសង់ពីរជាន់ ស្ថានហ្នឹងហើយដែលហៅសាលាវិទ្យាល័យស៊ីសុវត្ថិ នឹងស្ថានហ្នឹងហើយជាសាលាជាន់ខ្ពស់បំផុតនៅស្រុកខ្មែរ ។ ផ្ទះមួយទាបដំកូលដូចក្រចាប់នៅចំកណ្ដាលប្របកំពែងមុខជាប៊ុយរ៉ូលោកបាងហ្កាង ។ ផ្ទះធំទាំងអស់មានព្រាមួយខ្នង នោះផ្ទះបួនសង់ជាវង់បតុរង្សផ្ទុំលានធំទូលាយដែលជាទីសំរាកលេងសប្បាយនៃកូនសិស្ស ។ ផ្ទះពីរទៀតសង់បន្តគ្នាពុះក្រឡាចត្វង្សខ័ណ្ឌជាពីរស្មើ ជាទីស័យនដ្ឋាននៃកូនសិស្សដែលបានអាហារូបករណ៍នាជាន់លើ ។ ជាន់ក្រោមជាទីភិលល្អ សំរាប់ឲ្យកូនសិស្សជ្រកភ្លៀង ជាភោជនដ្ឋាន នឹងជាទីង៉ានសាលា ។ នៅចុងជួរផ្ទះនេះ ទាំងសងខាងមានរោងបុងភោពីខាងជើង នឹងរោងប្រកបការរៀនធ្វើការឈើពីខាងត្បូង ។

ផ្ទះតាមក្បែរខ្សែពត្ត័ង្សស្រឹងជាកន្លែងរៀន ចែកជាសាលាប្របឋមភូមិជាន់ខ្ពស់ មានថ្នាក់ទី៦ទី៥ទី៤ និងទី៣ សំរាប់កុមារស្រុកអាយ សាលាប្របឋមភូមិជាន់ខ្ពស់មានថ្នាក់ដូចគ្នា សំរាប់កុមារបារាំងសែស និងសាលាមធ្យមសិក្សាទំនើបសំរាប់ជាតិ ។ ផ្ទះពីរធំល្មមមួយៗ នៅមុំបត្ត័ង្ស នោះផ្ទះខាងត្បូងជាលំនៅលោកចាងហ្វាង ផ្ទះមួយទៀតលោកចាងហ្វាងរងជាមួយនឹងលោកអ្នកគ្រប់គ្រងសាលា ។ ផ្ទះពីរខ្នងដែលអមលានរាលទទេ សឹងជាសាលាចែកជាបន្ទប់អប់រំនៃកូនសិស្ស បន្ទប់រៀនគូរ បន្ទប់រៀនគីមី បន្ទប់រៀនសាកពិសោធវត្ថុរូបរាងកាយនៃមនុស្សនិសត្វ, រុក្ខជាតិផ្សេងៗ និងបន្ទប់រៀនភូមិសាស្ត្រ ។

កាលបើគេឈរមើលពីជាន់លើ គេឃើញលានសាលាវិទ្យាល័យជាសួនឧទ្យាន មានស្មៅខៀវស្រងាត់ដូចកំរាលដ៏ហើយនៅគំនូរដោយខ្សែត្រង់ ខ្សែកោង ខ្សែវង់ ខ្សែទាក់ក្រឡាប្រមុះជ្រុកបត្ត័ង្ស ត្រីកោណ គឺផ្ករពណ៌ក្រហមស៊ីគ្នានឹងផ្ទៃស្មានខៀវ មានគុម្ពបុប្ផាច្រើនបែបជាភ្ញីសម្រិស់ រុក្ខាស្រោងស្រឹងតាំងមានជួររងរត់រលោញ ដ៏មានស្លឹកបាស់ខ្ចីរលេចនឹងផ្លែផ្កា គណនាដូចនន្ទឧទ្យាន

ជាទីសិក្សានៃអ្នកសិក្សា ដូច្នេះបួនអ្នកវាស់គ្នាទំឡើងបានមករៀននៅស្ថាននេះ ។

---

**ជម្ជ្រាន** — សុំលៃបទនេះជាពីរ លុះដល់សព្វាហៈចុងបំផុត គប្បីបង្រៀនបទទាំងមូល ដើម្បីធ្វើជាគំរូតែងសេចក្តី ។ Texte = បទ

**ពាក្យពន្យល់**.— វិទ្យា + អាល័យ = វិទ្យាល័យ = ទីលំនៅនៃវិជ្ជា ។ បុណ្ណ + អាល័យ = បុណ្ណាល័យ = ទីស្ថិតនៃគម្ពីរ ។ ចតុរង្ស = ចតុរស្ស = បួនជ្រុង; ចតុរង្ស = ដូចគ្នានឹងចតុរង្ស ។— ស័យនដ្ឋាន = ផ្ទះសម្រាប់ដេក ។ — ភោជនដ្ឋាន = កន្លែងសំរាប់បរិភោគ ។— សាលាប្រថមភូមិជាន់ខ្ពស់ — primaire supérieur ។ - សាលាមធ្យមសិក្សាទំនើបសំរាប់ជាតិ secondaire moderne national ។— អ្នកគ្រប់គ្រង =économe ។ បន្ទប់អប់រំ = salle-d'études ។ — បន្ទប់គីមី = salle chimie ។ — បន្ទប់សាកពិសោធ = salle de sciences d'observations ។ ឧទ្យាន = សួន ។— នន្ទឧទ្យាន = សួនព្រះឥន្ទ្រាធិរាជ ។— ស៊ុក្កា — ផ្ទះទល់គ្នា ។ បុប្ផា ឬ បុស្បា = ផ្កា ។ អាហារូបករណ៍ bourse សុំឲ្យលោកគ្រូតែងពាក្យចោទសួរផងចុះ ។

---

## មជ្ឈដ្ឋានទី ២

### កីឡា

កីឡាជាល្បែងសម្រាប់កំសាន្តចិត្ត ប៉ុន្តែជាល្បែងកាយពលដែរ ។ ល្បែងទាំងឡាយនោះមានមកតាំងពីបូរាណ ពីជាន់ណា ៗ នឹងកំណត់កាលគ្រាពុំបានផង ។

គឺជាល្បែងអាចបន្ទោបង់សេចក្តីអផ្សុក នឹងអាចឲ្យសិទ្ធិកម្មសំ-
រេចប្រយោជន៍ថ្មីក្នុងការសព្វសារពើទាំងពួង នឹងឲ្យកើតបិត្តបញ្ញា
ជ្រះថ្លាដោយសារកំសាន្ត ព្រមនឹងមានសរីរៈរាងកាយមាំពូកែផង។
នៅក្នុងកម្ពុជរដ្ឋយើងនេះ កាលសម័យជាន់បុរាណដែលទើបនឹង
ផុតទៅ ពីរជ្ជកាលព្រះបាទស៊ីសុវត្ថិមក មានមនុស្សលឿន មនុស្ស
រហ័ស មនុស្សខ្លាំងហួសប្រមាណ មនុស្សហ៊ានរងមុខអាវុធ ខះខ្វែន
ធ្នូគុនដាវវែង គុនល្បុកតោ គុនដំបង ខះវត់មិនហត់ ខះប្ញកខាងស៊ីផឹក
ស៊ីពែន ស៊ីមីលោង ប្ញកខាងវាយកូនគោលនឹងកាប់អំពៅ ។

ល្បែងកូនគោលជាល្បែងមានសណ្ឋានណាំ ៗ នឹងល្បែងបាល់
សព្វថ្ងៃ ប៉ុន្តែគេលេងល្បែងនេះតែវេលាយប់ ។ នឹងលេងល្បែង
នេះ គេតាំងក្រុមបក្សាមិត្រជាពីរពួក បំនួនតិបច្រើនតាមបាន ឲ្យតែ
ស្មើគ្នាដោយបំនួនមនុស្ស ។ អ្នកលេងសឹងកាន់ដំបងប្រវែងមួយ
ព្យាមហើយដណ្តើមគ្នាវាយប្រតាយឲ្យកូនគោលបានមកទីខ្លួន ។
កូនគោលនោះជាដុំឈើរលួសស្ងួតដុតឲ្យឆេះ ជាងធើកក្រហមទំហំ
ប៉ុនផ្លែញ្ញោធំ ។ ទីដែលលេងជាដីរាបជាបគ្នាត់ ប្រវែងស្រែធំ
ល្មមមួយ ។ គេចែកទីជាពីរស្មើ តែដាក់កូនគោលត្រង់កណ្តាល ។

អ្នកលេងទាំងឡាយនោះឈរសងខាងបន្ទាត់ កាយគ្នាជាជួរពីស្ដាំទៅឆ្វេងតាមបន្ទាត់ ។ នោះអ្នកដើមទីគឺត្រង់ទីដែលកូនគោលនៅនោះ លើកដំបងប្រុង លុះឮបង្គាប់ថា "ហ៏" ក៏វាយប្រដាយគ្នាឲ្យកូនគោលរត់ទៅឆ្វេងរាល់ខ្លួន វាយបញ្ជូនឲ្យគ្នា ពួកម្ខាងដេញដណ្ដើម វាយដ៏មានសូរដំបងពុំដែលដាច់ ងើកភ្លើងបែកព្រាយ ៗ បើខាងណាឈ្នះ គេវាយយកបាននាំរហូតបុងទី ជយោ! លាន់ឮសាន ដោយសប្បាយនឹងឈ្នះ ។

ល្បែងទាំងឡាយបន្ដោបង់សេចក្ដីអផ្សុកនឹងសំណឹកខ្លួន ប៉ុន្ដែត្រូវកុំប្រព្រឹត្តឲ្យហួសប្រមាណ ទាល់តែគេហៅថាអ្នកឆ្កួតល្បែងនោះឡើយ ។

---

ដម្បូន្មាន.— Texte=បទ សុំឲ្យលៃបទនេះជាពីរ ។ ខាងដើមដល់....កាប់អំពៅ ខាងចុង... តទៅទៀតដល់ចប់ ។ ក្នុងសប្ដាហ៍បំផុត គប្បីរៀនបទទាំងមូលវិញ ដើម្បីរៀនជាតំរូតែងសេចក្ដីផង ។

អានពាក្យ.— កាយពល (កា–យះ–ពល់) ។ សរីរ (សៈ–រី–រះ)

ពាក្យពន្យល់.— កីឡា = ល្បែងហាត់ប្រាណ ។ – កាយពល = កំឡាំងខ្លួន។– សិទ្ធកម្ម = សំរេចកិច្ចធ្វើ ។ – ថ្នឹក = ធ្លាប់, ប្រសប់ ។ – ខ្វិន = ថ្នឹកប្រសប់ ។– បត្យាមិត្ត ឬ បច្ចាមិត្ត = សត្រូវ ។ – គុន = របៀប វាយដោយដំបង ឬ កាប់ដោយដាវ

តាមក្បួនកោត់ ។ — គុនល្បុកគោ = អ្នកគុនកាន់កាំបិតពីរ ។ — កាប់អំពៅ = កាប់អំពៅតាំងជាប់តែមួង គឺមួយកាំបិតឲ្យដាច់ទាំងអស់ ។ — ធ្លូតល្បែង = លេងទាល់តែក្ងេចធ្វើបររកស៊ុ ។ ធ្លូតមានបី គឺធ្លូតស្រី, ធ្លូតស្រា, ធ្លូតល្បែង ។

ពាក្យចោទសួរ.— អ្នកស្គាល់ល្បែងអ្វីខ្លះ? — ក្នុងសាលាគេបង្ហាត់ល្បែងអ្វី? ល្បែងឲ្យគុណដូចម្តេច? (គឺថាមានប្រយោជន៍ដូចម្តេច)— ល្បែងឲ្យទោសដូចម្តេច?— បៀ, អាភៀន ជាល្បែងដែរឬអ្វី? ល្បែងទាំងនេះត្រូវកាន់យក ឬ ត្រូវវៀរចាក? — ហេតុអ្វី ។

## មជ្ឈិមដ្ឋានទី ១

### ត្រូវសំចៃអណ្តាត

ហ៊ុំជាក្មេងមាត់ពេក ។ នៅក្នុងបន្ទប់រៀន ការដែលត្រូវស្តាប់ ឬត្រូវមើលអ្វីដែលគ្រូសរសេរលើក្តារខៀន ហ៊ុំវាប្រែខ្សៀវនឹងគ្នាជិតខាងរវ៉ូវ ។ វាធាធារគេ ធ្វើឲ្យគេជាប់ទោសដូចវាផង ។ ព្រឹកមិញហ៊ុំធ្វើអំពើឲ្យអត់ពុំបានជាងធម្មតា នោះគ្រូក៏ស្តីប្រដៅហើយសួរថា៖

ហ៊ុំ, ឯងមានត្រចៀកប៉ុន្មាន?— លោក, ខ្ញុំបាទមានត្រចៀកពីរ ។

ឯងមានភ្នែកប៉ុន្មាន?— ខ្ញុំបាទមានភ្នែកពីរ ។

ចុះឯងមានអណ្តាតប៉ុន្មាន?— លោក, ខ្ញុំបាទមានអណ្តាតមួយ ។

ចុះហេតុអ្វីក៏ឯងមានអណ្ដាតតែមួយ មានត្រចៀកពីរ មាន ភ្នែកពីរ?– លោក, ខ្ញុំបាទពុំដឹងទេបាទ ។

ចូរឯងរំពឹងមើល, ភ្នែកប្រើការធ្វើអ្វី?– បាទលោក, ភ្នែក សំរាប់មើលសំគាល់ ។

ចុះត្រចៀក?– បាទលោក, ត្រចៀកសំរាប់ស្ដាប់ ។

ចុះអណ្ដាត?– បាទ, អណ្ដាតសំរាប់និយាយ ។

អើន៍! បើឯងមានភ្នែកមួយគូ មានត្រចៀកមួយគូ អណ្ដាត មួយ នោះត្រូវឯងប្រើភ្នែកនឹងមើលជាងអណ្ដាតពីរដង ប្រើត្រចៀក នឹងស្ដាប់ជាងអណ្ដាតពីរដង អណ្ដាតត្រូវនិយាយតែមួយដង ។

ហ៊ីរអៀនផ្កាក់ទឹកមុខ ព្រោះធ្លាប់តែប្រើអណ្ដាតជាងភ្នែកនឹង ត្រចៀក វាសូមលន្លួហើយសន្យាថានឹងកែមារយាទតទៅ ។

---

ពន្យល់ពាក្យ.– សំចៃ= ប្រើការមិនឲ្យអស់ គឺទុកឲ្យមានសល់ ។– ឆាឆារ រើរុះដោយអំពើផ្សេង ៗ– លន្លួ (លន់-លួ)-សុំឲ្យអត់ទោស ។ សន្យា (សន-ន្យា)= កំណត់ ណាត់កាលនឹងធ្វើអ្វីមួយ មាយាទ ឬ មារយាទ (មា-រៈ-យាទ) ឥរិយា ។–មាត់ពេក = និយាយ ច្រើនពេក ។ texte = បទ

ពាក្យសួរ.– ១) ហ៊ីរផៈ ក្មេងដូចម្ដេច?– ២) ព្រឹកមួយនោះគ្រូធ្វើអ្វីដល់ហ៊ីរ?– ៣) គ្រូសួរហ៊ីរដូច្នោះដើម្បីអ្វី?– ៤) ហ៊ីរលន្លួដូចម្ដេច?– ៥) វណ្ណយុត្តិអ្វីខ្លះដែលប្រើការក្នុងបទនេះ?– ពាក្យណាខ្លះដែលកើតពីស្រៈពេញតួ ។

## គ្រាប់សម៉មួយ

ក្មេងម្នាក់ដើរទៅតាមផ្លូវមួយពាលថ្ងៃហែង ដែលសំដៅទៅលើសាលារៀន ។ ដោយដំណើរពាលថ្ងៃក្ដៅ ក្មេងនោះស្រេក-ទឹក ។ វាទាញយកផ្លែសម៉ដែលម្ដាយវាដាក់ឲ្យមកបៀមទាំងជញ្ជក់ រួចបោះពោលគ្រាប់ទៅ ។ តាចាស់ម្នាក់រើសយកគ្រាប់សម៉នោះ គាត់ជីកកប់ដាំទុក ។ ក្មេងឃើញតាចាស់ធ្វើដូច្នោះ វាសើចហើយនឹកថា ឱតានេះ! គាត់ដាំសម៉បំបង់កម្លាំងមែនពិត គាត់ចាស់ម្ល៉េះទៅហើយ ។ លុះយូរបន្តិចមក ដោយក្មេងនោះឯងដើរទៅមកតាមផ្លូវដដែល វាប្រទះកូនឈើដុះនៅកន្លែងដែលតាចាស់កប់គ្រាប់ ឃើញតានោះនៅ ៗ ឡើយដែរ គាត់កំពុងតែថែទាំមើលក្រែងដ្លូងដង្កូវស៊ី ។ ក្មេងដំទង់នោះនឹកថា ហេតុអ្វីតានេះគាត់ប្រឹងបំបង់កម្លាំងយ៉ាងនេះ ។

ប៉ុន្តែលុះវ័យបំរើនធំឡើងជាមនុស្សភាពពេញលេញហើយ មានកាលមួយនោះ មនុស្សនោះត្រូវទៅតាមផ្លូវដ៏ហើយនៅខ្វាប់ ដើម្បីទៅសួរគ្រូដើមរបស់ខ្លួន ក៏ឃើញដើមសម៉ធំល្អត្រសុំត្រសាយ ដ៏មានផ្លែះយានយាន បុរសនោះក៏បេះមកទាំជញ្ជក់បង្អន់សម្រេកទឹក ទើបមនុស្សនោះយល់ថា ឱ សេចក្ដីសន្ដិប័យនៃតាចាស់ជាការប្រសើរ ។

ពាក្យចោទសួរ.— ១) ក្មេងភានឹកថា តានោះដាំបង់កម្លាំង នោះតើដោយភាយល់ដូចម្ដេច ។— ២) លុះឯក្រោយបង្អស់ភាឃើញឈើផ្លែផ្កា នោះតើនឹកថាដូចម្ដេចវិញ ។ ៣) រឿងនេះឲ្យបទដម្បូន្មានដូចម្ដេច ។— ៤) ពាក្យណាខ្លះដែលកើតពីស្រៈ ៉ ?— ដែលមានដាច់ដោយបន្តក់ ?— ពាក្យណាខ្លះដែលត្រូវព្យាង្គ ?— ហេតុអ្វីពាក្យទាំងនោះតម្រូវគ្នា ។

ពាក្យពន្យល់.— បំបង់កម្លាំង=ធ្វើឲ្យបង់កំឡាំង ។ សន្និច័យ= សន្សំ (Prévoyance

---

អាទិកដ្ឋាន

## បង្រៀនមើល-បង្រៀនពាក្យ-ហាត់ភាសា

អាទិត្យទី១ = ១— ក្មេងបេះធ្វើឲ្យឪពុកម្ដាយសប្បាយចិត្ត សៀវភៅរៀនខេមរភាសាអាទិកដ្ឋាន ទំព័រទី ១ ។

នាម.— ឪពុក ក្បាល សៀវភៅ ទំព័រ មេរៀន សត្វចាប សំឡេង បង្អួច ដើមត្របែក ប្រក់ផ្ទះ រូ ខ្វែង ។

គុណនាម.— ក្រាស ស្ដើង វែង ខ្លី ពីរោះ ទុំ ក្រហម ក្រអូប ល្អ ទោរទន់ ។

កិរិយាសព្ទ.— ឱនក្បាលចុះ ទំមើលមេរៀន យំសំឡេងពីរោះ ស្ដាប់សំឡេងចាបយំ លេងរូ បង្ហូរខ្វែង ស្រែក សើច ធ្វើមិនដឹង ។

*ពន្យល់ពាក្យ*.– ធ្វេស=បណ្ដែតទុក ឬរំលងទុកធ្វើជាក្រោយ។ ក្បែរ= ជិត.– មិនរវល់= មិនអើពើ;– ទោរ= គោង, ទ្រេត ប្រកផ្ទះ= បន្ទោះផ្ទះ; –វី= វត្ថុជាល្បែងក្មេង ១ យ៉ាង; ពីរោះ= សំឡេងគាប់ត្រចៀកគួរឲ្យបង់ស្ដាប់ ។

*សូមកែពាក្យខុស*.– ទុំពារ៊–មឹន–គឹត=ទុំពារ–មិន–គិត ។

បទវេយ្យាករណ៍.– ប្រាប់–ស្ដាប់–ឱល់–បង់–បប់–អស់ (សញ្ញាបន្តក់លើស្រៈអា–អ) ។

*ហាត់កថា*.– ក្នុងរឿងនេះគេនិយាយពីអ្វី? ចាបជាសត្វដូចម្ដេច? ចាបក្នុងរឿងនេះវាទំនៅឯណា?– ដើមត្របែកនៅឯណា?– មានអ្វីនៅលើដើមត្របែក?– មានអ្វីនៅប្រកបន្ទោះផ្ទះ?– ចៅដួនមានបំណងបង់ស្ដាប់សំឡេងចាប – បេះត្របែកទុំ – បង្ហើរខ្លែង – លេងវីដែរឬទេ? ។

*អាទិត្យក្រោយ* – អំពីក្រុមញាតិ (ត)

សុំធ្វើតាមរបៀបអាទិត្យមុន

បិទ មានន័យជាដូចម្ដេច?– បិត....។.. ..(បិទទ្វារ–រិទបង្អួចបិទឲ្យជិត:– បិតបន្ទោះឫស្សី – បិតផ្ដៅ) ក្នុងរឿងមើលពាក្យណាខ្លះដែលមានសញ្ញាបន្តក់? ។

របៀបបង្រៀន — និងបង្រៀនមើលត្រូវធ្វើរបៀប = ក) គ្រូមើលសូត្រជាដំបូង ។ ខ) អានពាក្យពិបាក ។ គ) ពន្យល់ពាក្យពិបាក ។ ឃ) សិស្សមើល ។ ង) ចោទសួរឲ្យយល់សេចក្ដី ។ ក្នុងបទចោទសួរ ត្រូវធ្វើបំណោទបីឬបួន នោះត្រូវចោទសួរ ១–អំពីគ្រោងរបស់រឿង គឺរឿងនោះគេនិយាយពីអ្វី ។ ២–សព្ទរបស់ពាក្យមួយ ៗ ពីរឬបីពាក្យ ។ ៣– ន័យរបស់ពាក្យពិបាកមួយឬពីរបីពាក្យ ។ ៤–បទវេយ្យាករណ៍១បទ ។

## ២ – ត្រូវមកសាលារៀនឲ្យទាន់ពេលវេលា

*សៀវភៅវិជ្ជាខេមរភាសាអាទិកដ្ឋានទំព័រទី២*

នាម.– *សាលារៀន ស្គរ ពេលវេលា ម៉ោង មីនុត ។*

គុណនាម.– *រហ័ស យឺតយូរ លឿន*

កិរិយាសព្ទ.– *ដើរទៅសាលារៀន ជួបនឹងគូកន ឈប់បន្តិចលេង បានពីរឬបីមីនុត ឮស្គរ ដល់ម៉ោង ។*

ហាត់ភាសា.– *ចៅព្រំដើរទៅឯណា? ក៏ជួបនឹងអ្នកណា? គូកនវ៉ាឈ្មោះអ្វី? គឹមនិយាយថាដូចម្ដេច? ចៅព្រំឆ្លើយថាដូចម្ដេច? ក្នុងសេចក្ដីនេះគេប្រាប់ឲ្យធ្វើដូចម្ដេច? ។*

### ចូរធ្វើប្រយោគនឹងពាក្យមួយម៉ាត់ៗខាងក្រោមនេះ

សាលារៀន ៗ ស្គរ ៗ រៀន ៗ យឺតយូរ ៗ ខ្ញុំទៅសាលារៀនរាល់ថ្ងៃ ៗ នៅក្នុងសាលារៀនខ្ញុំមានស្គរមួយ ៗ ខ្ញុំខំរៀនឲ្យបានចេះឆាប់ ៗ ខ្ញុំដើរឲ្យលឿនប្រយោជន៍កុំឲ្យទៅដល់សាលារៀនយឺតយូរ ៗ

### ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោមនេះ

កូនសិស្សមិនត្រូវមកសាលារៀនឲ្យ ...... ពេកឬឲ្យ ........ ពេកទេ ៗ កូនសិស្សត្រូវមកឲ្យ ......... ម៉ោង ហើយមិនត្រូវប្រឡែងគ្នាលេង ............ (នៅកណ្ដាលផ្លូវ) ទេ ៗ

## សរសេរតាមសូត្រ

សូមជ្រើសរើសយកសេចក្ដីក្នុងមេរៀន ដែលបានបង្រៀនមើលខាងលើនេះ ចំនួនបួនប្រាំបន្ទាត់មកឲ្យសិស្សសរសេរតាមគ្រូថាផងចុះ ប៉ុន្តែសូមធ្វើតាមរបៀបបញ្ជាក់ដាក់អក្សរត្រឹមត្រូវតាមគ្រូថា ដែលមានចុះក្នុងទស្សនាវដ្ដីទី១ ខែសេបតមប្រ៍ ឆ្នាំ ១៩៤៩ នេះ

## តែងសេចក្ដី

ចូរអ្នកអធិប្បាយ អំពីកូនសិស្សឧស្សាហ៍រៀនសូត្រណាម្នាក់ ដែលអ្នកបានស្គាល់ពិតប្រាកដ ៗ

*ទំនងថែម*

១– *សេចក្ដីផ្ដើម*.– អ្នកស្គាល់កូនសិស្សណាម្នាក់ឧស្សាហ៍រៀនសូត្របឬទេ ។

២– *សេចក្ដីកង់រៀង*.– សិស្សនោះឈ្មោះអ្វី? – អាយុវាប៉ុន្មានឆ្នាំ វារៀននៅថ្នាក់ណា? វាចាំមេរៀនស្ទើញឬទេ? វាធ្វើដូចម្ដេចខ្លះ នៅសាលារៀន-នៅផ្ទះ?

៣– *សេចក្ដីបញ្ចប់*.– អ្នកប្រង់យកដំរាប់វាឬទេ? ពីព្រោះអ្វី? ។

*ការចំណាំ* = មុននឹងឲ្យសិស្សតែងពាក្យឆ្លើយដាក់សៀវភៅ សូមលោកគ្រូសួរបោះទាំវាឲ្យឆ្លើយមាត់ទទេឲ្យត្រឹមត្រូវសិន ។

អក្សរផ្សង់

ក ភ គ ត ឥ ត្រៀ

ភ ភា ភី ភូ ភួ ភើ ភេ ភែ

ភៅ ភុំ ភុំភឿន រកភួយ កុំភិតភែ

អាទិត្យទី២

បង្រៀនពាក្យ-ហាត់ភាសា

# អំពីក្រុមញាតិ

នាម.– ឪពុក (បិតា) ម្ដាយ (មាតា) កូន បងប្អូន កូនច្បង កូនបន្ទាប់ កូនពៅ កូនខ្ទី កូនប្រុស កូនស្រី រៀមច្បង ក្រុមញាតិ ញាតិសន្ដាន ។

គុណនាម.– ក្មេង ចាស់ តូច ធំ កំឡោះ ក្រមុំ ជំទង់ ។

កិរិយាសព្ទ.– កើតកូន ឆ្លងទន្លេ សម្រាលកូន ប្រសូត ថែទាំ-រក្សា រកចិញ្ចឹមកូន បំពេកូន លួងប្អូន ពប្អូន បំបៅកូន ផ្ដេកកូន ។

ហាត់ការ.– ក្រុមញាតិអ្នកមានមនុស្សប៉ុន្មាននាក់? មាតាបិតាអ្នកអាយុប៉ុន្មានឆ្នាំហើយ? អ្នកមានបងប្អូនប៉ុន្មាននាក់? អ្នកណាជាកូនច្បង? កូនពៅឪពុកម្ដាយនាក់ប្រុសឬស្រី? យ៉ាងដូចម្ដេចដែលហៅថាកូនកំឡោះ?–កូនក្រមុំ?–យ៉ាងដូចម្ដេចហៅថាកូនជំ-ទង់?–កាលណាប្អូនអ្នកយំអ្នកធ្វើដូចម្ដេច?– ម្ដាយអ្នកធ្វើម្ដេច?– ហេតុអ្វីបានជាឪពុកម្ដាយអ្នកទៅធ្វើការរាល់ថ្ងៃ? តើអ្នកស្រឡាញ់ឪពុកម្ដាយអ្នក-បងប្អូនអ្នកឬទេ? ។

វិធីហាត់សរសេរ.– សូមយកពាក្យចោទសួរ ៣ ឃ្លាខាងលើនេះមកដាក់ឲ្យសិស្សឆ្លើយផងចុះ ។

## បង្រៀនមើល

១– អំពីនៅជួបជុំក្រុមញាតិក្នុងវេលាយប់

សៀវភៅវិជ្ជាខេមរភាសាបរិបូណ៌ថ្នាក់ទំព័រ ៤៦

ពន្យល់ពាក្យ.– អាស្រ័យ (សុំ - ទទួលទាន - បរិភោគ) ព្យួរនៅពិតាន ដេញបាចុំ និទានរឿងព្រេង ។

២– សេចក្ដីស្នេហានឹងបងប្អូនបង្កើត

សៀវភៅវិជ្ជាខេមរភាសាអាទិកថ្នាក់ទំព័រ ៩

## សរសេរតាមសូត្រ

សេចក្ដីស្នេហានឹងបងប្អូនបង្កើត

សៀវភៅដដែលទំព័រ ៩ តាំងពីបន្ទាត់ដើម . . . ដល់ . . . ឲ្យនឿយលំបាកខ្លួនឯងយ៉ាងដូច្នេះ ។

ពន្យល់ពាក្យពីបាក.– ស្នេហា (ស្នែហា)–ប្អូន (បជើងអ)–បង្កើត (ព្យាង្គគតម្រួត)– ដម្បី (មជំនួសៈ) – បបរ (រ) កើរ (រ) ក៏ (៎) ម្នាក់, ណាស់, ដល់, បាស់ ។

វេយ្យាករណ៍=បន្តក់ ( ់ ) ប្រើលើពាក្យកើតពីស្រៈ អ អា ហើយសព្វទី ។ បន្តក់ស្ថិតលើអក្សរប្រកប ។ អក្សរដែលទទួលបន្តក់បាន= ក ង ប ញ ត ន ប ល ស ។

## តែងសេចក្តី

*ដូចបានពណ៌នាមកហើយថា នៅខែដម្បូង(ត្រូវធ្វើ)នូវសំសរឲ្យចេះរក ចំនងតែងសិន ។ ឲ្យតែងតាមមើលសង្កេតរូបគំនូរ ។*

### អំពីនៅជួបជុំក្រុមញាតិក្នុងវេលាយប់

*សៀវភៅវិជ្ជាខេមរភាសាបរិបូណ៌ថ្នាក់ទំព័រ ៤៧*

### ទំនងតែង

១–សេចក្តីផ្តើម.— *ក្នុងរូបភាពនេះមនុស្សប៉ុន្មាននាក់ ហើយមានអ្វីផ្សេងៗនៅខាងលើ – មនុស្សទាំងអស់នេះគឺអ្វី ។*

២–សេចក្តីរាប់រៀប.– *នៅចុងតុខាងស្តាំមានអ្វី-ស្លៀកពាក់ដូចម្ដេច អង្គុយលើអ្វី- ធ្វើអ្វី - ហើយនៅជិតនោះមានអ្វី - រូបរាងដូចម្ដេច - អង្គុយលើអ្វី ធ្វើអ្វី? ។ អ្នកណាអង្គុយនៅខាងឆ្វេងតុ - ធ្វើអ្វី - ធ្វើដៃដូចម្ដេច - ហើយនៅខាងមុខមានអ្នកណាខ្លះឈរ - ធ្វើអ្វី? ។ នៅបន្ទាប់ហើយខាងស្តាំដៃ មានអ្នកណា - ឈរឬអង្គុយ - ម្ដាយកំពុងធ្វើអ្វី ហើយនៅខាងចុងបំផុតមានអ្នកណា -អង្គុយធ្វើអ្វី? ។*

៣– សេចក្ដីបញ្ចប់–យោបល់.– *អ្នកយល់ឃើញថាដូចម្ដេច គ្រួសារនេះ - ពីព្រោះអ្វី ។ (ប្រយ័ត្នកុំឲ្យចម្លងសេចក្ដីរៀនក្នុងសៀវភៅ) ។*

---

បរិច្ឆណដ្ឋាន

## បង្រៀនមើល

*បង្រៀនមើលតាមសៀវភៅផ្កាខេមរភាសាថ្នាក់បរិច្ឆណដ្ឋាន និងថ្នាក់អាទិកដ្ឋានតាមទំព័រដូចមានក្នុងកិច្ចសិក្សានេះ លោកគ្រូត្រូវចែកសេចក្ដីមើលនោះបែងជា ៤ អាទិត្យ ។*

## បង្រៀនពាក្យ - ហាត់ភាសា

### ១ – អំពីផ្ទះ

នាម.– ផ្ទះ - សសរ - ជញ្ជាំង - ដំបូល - មេដំបូល - រងស្បូវ-ផ្ទាន - ផ្ទោង - បង្កង់ - ដៃរណែង - រនង - រន្ធត - រនាប - ក្ដារ - ទ្វារ - បង្អួច - ជណ្ដើរ ។

គុណនាម.– ទាប - ខ្ពស់ - ធំ - តូច - បង្អៀត - ទូលាយ - មូល - សំប៉ែត - មាំ - ស្អាត - ក្រខ្វក់ - រៀប - ត្រង់ - ទ្រេត ។

កិរិយាសព្ទ.— សង់ផ្ទះ - រុះផ្ទះ - លើកសសរ - ធ្វើជញ្ជាំង- វាយផ្ដាន - ផ្តោង - បង្កង់ - បោះដែរណែង - រនង់ - រនូត - រនាប - បោះក្ដារ- (ក្រាលក្ដារ) ។

ហាត់ភាសា.— *ផ្ទះអ្នកសង់នៅភូមិណា - ក្នុងឃុំ - ខេត្តណា ។ ផ្ទះអ្នកសង់អំពីអ្វី ។ សសរផ្ទះអ្នកយ៉ាងដូចម្ដេច មានសសរប៉ុន្មានជួរ ។ ជញ្ជាំងមានកំពស់ប្រហែលប៉ុន្មានម៉ែត្រ ។ ផ្ទះអ្នកប្រក់អ្វី ។ ចូររាប់រៀបរៀងផ្ទះខាងលើទាំងអស់មើល ។ ផ្ទះអ្នកក្រាលរនាបឬក្ដារ ។ មានទ្វារនិងបង្អួចប៉ុន្មាន ។ ផ្ទះអ្នកខ្ពស់ឬទាប ។ ទូលាយឬចង្អៀត ។ ផ្ទះអ្នកស្អាតឬទេ ។ ពីព្រោះអ្វីបានជាស្អាត ។ ផ្ទះអ្នកសង់បែរមុខទៅទិសខាងណា ។ អ្នកពេញចិត្តនឹងផ្ទះអ្នកឬទេ ។ ព្រោះអ្វី ។*

## ២— អំពីវត្ថុដែលយកមកសង់ផ្ទះ

នាម.— ឈើ - ដែក - ឥដ្ឋ - ស៊ីម៉ង់ត៍ - កំបោរបូ - ក្រួស - ខ្សាច់ - គ្រឿង - ឬស្សី - ផ្តៅ - វល្លិ ។

គុណនាម.— ធ្ងន់ - ស្រាល - ម៉ដ្ឋ - គគ្រាត - សព្វ - រឹង - ទន់ - ស្រួយ - ស្ងួត - ស្ងួត - ស្រស់ ។

កិរិយាសព្ទ.— កាប់ឈើ - ច្នឹងដែក - វែកឥដ្ឋ - វែងក្រួស - សែងស៊ីម៉ង់ត៍ - កើបខ្សាច់ - លាយកំបោរ - យកវល្លិ ។

ហាត់ភាសា.— *ដើម្បីនឹងសង់ផ្ទះគេត្រូវការវត្ថុអ្វីខ្លះ ? ឈើគ្រឿងផ្ទះតើអ្វីខ្លះ ? ដើម្បីនឹងឲ្យគ្រឿងផ្ទះមាំ គេត្រូវការរបស់អ្វីយកមកប្រើទៀត ? ជាងសង់ផ្ទះប្មត្រូវការវត្ថុអ្វីខ្លះ ? ជាងត្រូវធ្វើអ្វីមុន ដើម្បីនឹងរៀបគធ្វើជាសសរឬជញ្ជាំងឲ្យខ្ពស់ ? គេធ្វើនឹងអ្វី ? ខ្ភប់ដែលជាងយកមកសង់ផ្ទះយ៉ាងដូចម្តេច ? ចុះក្រសវិញ ?*

## ៣.— អំពីក្រុមញាតិ

នាម.— ឪពុក (បិតា) ម្តាយ (មាតា) កូន-បងប្អូន-កូនច្បង-កូនពៅ-កូនខ្ចី-កូនប្រុស-កូនស្រី-រៀមច្បង-ក្រុមញាតិ ញាតិសន្តាន ។

គុណនាម.— ក្មេង-ចាស់-ធំ-តូច-កំឡោះ-ក្រមុំ-ពេញ ធំទង់-បងប្អូនបង្កើត ។

កិរិយាសព្ទ.— កើតកូន-ឆ្លងទន្លេ-សម្រាលកូន-ថែរក្សា ចិញ្ចឹមកូន-បំពេកូន-លួងកូន-ពប្អូន-បំបៅកូន-ផ្តេកកូន-បញ្ចុក បាយកូន-នាំកូនលេង ។

ហាត់ភាសា.— *ក្រុមញាតិអ្នកមានប៉ុន្មាននាក់ ? មាតាបិតាអ្នកអាយុប៉ុន្មានហើយ ? អ្នកមានបងប្អូនប៉ុន្មាននាក់ ? អ្នកណាជាកូនច្បង ?*

កូនចៅឪពុកម្តាយអ្នកប្រុសឬស្រី ។ ដូចម្តេចហៅថាកូនកំព្រា ។ ចុះកូនក្រមុំ ។ យ៉ាងដូចម្តេចហៅថាកូនពេញជំទង់ ។ កាលណាប្អូនអ្នកយំ អ្នកត្រូវធ្វើដូចម្តេច ។ អ្នកស្រឡាញ់ឪពុកម្តាយ បងប្អូនអ្នកឬទេ ។

## ៤.– អំពីក្រុមញាតិ (ត)

នាម.– ជីតា-ជីដូន-ឪពុកធំ-ម្តាយធំ-មា-ម្តាយមីង-ចៅ-ក្មួយ-បងប្អូនជីដូនមួយ-ចៅបង្កើត ។

គុណនាម.– ចាស់ព្រឹទ្ធាចារ្យ-ចាស់ជរា-សក់ស្កូវ-ស្បែកជ្រីវជ្រួញ-ថ្ពាល់ខួង-ខ្នងកោង-ញ័រ (ដៃ-ជើង) ស្ងួត-ខ្សោយ ។

កិរិយាស័ព្ទ.– ទទួលអនិច្ចកម្ម (ខូច-ស្លាប់) ជួយទំនុកបំរុង-គោរពប្រតិបត្តិ-ទូន្មាន-ប្រដៅ-ដេក-ដើរ-ឈរ-អង្គុយ ។

ហាត់ភាសា.– ជីដូនជីតាអ្នករស់នៅសព្វថ្ងៃឬទេ ។ ជីដូនជីតាអ្នកទទួលអនិច្ចកម្មពីកាលណា ។ ឪពុកម្តាយអ្នកនៅមានបងប្អូនដែរឬទេ ។ បងរបស់ឪពុកម្តាយអ្នកត្រូវជាម្តេចនឹងអ្នក ។ ដៃជើងមុខមាត់របស់ជីតាអ្នកដូចម្តេច ។ អ្នកគោរពរាប់ក្រុមញាតិរបស់អ្នកឬទេ ។ រាល់ថ្ងៃជីដូនជីតាអ្នកធ្វើអ្វីខ្លះ ។ អ្នកធ្វើអ្វីខ្លះជូនជីដូនជីតាអ្នក ។

ឯបង្រៀនពាក្យហាត់ភាសានេះមិនមែនមានតែប៉ុណ្ណេះទេ មានពាក្យឯទៀតច្រើន សូមលោកគ្រូជ្រើសរើសយកបង្រៀនសិស្សថែមទៀតផង ។

មួយទៀតបង្រៀនពាក្យអំពីវត្ថុដែលយកមកសង់ផ្ទះនោះ សូមលោកគ្រូយកវត្ថុនោះមកបង្ហាញសិស្សផងដែរ ។

---

## សរសេរតាមសូត្រ

សូមលោកគ្រូជ្រើសរើសយកតែងសេចក្តីដែលបានបង្រៀនមើលពីថ្ងៃមុន អំពីផ្ទះ និងអំពីក្រុមញាតិ ។

## តែងសេចក្តី

១.— ចូរអ្នកបន្ថែមត្រង់កន្លែងចន្លោះដូចមានខាងក្រោមនេះ ផ្ទះខ្ញុំនៅភូមិ..... ឃុំ..... ស្រុក..... ខេត្ត..... ហើយសង់នៅកណ្តាល..... ផ្ទះខ្ញុំសង់អំពី..... ប្រក់..... ជញ្ជាំងធ្វើអំពី..... នៅខាងមុខផ្ទះខ្ញុំមាន..... ហើយនៅជុំវិញមានដាំ..... ច្រើន ។

ផ្ទះខ្ញុំចែកជា..... បន្ទប់ ៗ ធំជាងគេគឺបន្ទប់..... នៅសងខាងបន្ទប់នោះគឺបន្ទប់..... នៅក្នុងបន្ទប់និមួយ ៗ ខ្ញុំឃើញមាន..... ។ ម្តាយខ្ញុំដាំបាយនៅ..... ដែលសង់នៅ..... ផ្ទះធំ..... មាន..... ភ្ជាប់ផ្ទះធំនិងផ្ទះបាយ ផ្ទះខ្ញុំ..... ហើយ..... រាល់ព្រឹកកាលណាខ្ញុំក្រោកពីដំណេក ខ្លួនខ្ញុំហើយបងប្អូនខ្ញុំ..... ផ្ទះពុំដែលខានទេ ដូច្នេះបានជាផ្ទះខ្ញុំ..... ណាស់ ។

២.— ចូរអ្នកបន្ថែមត្រង់កន្លែងចន្លោះដូចមានខាងក្រោមនេះ

ពីម្សិលមិញខ្ញុំបានទៅលេងក្នុងភូមិ ហើយបានប្រទះឃើញ····· មួយក្រុម កំពុងតែសង់ផ្ទះមួយ·····នៅទីវាលមួយយ៉ាងស្អាត ជាងខ្លះ·····ដីដើម្បីនឹងដាំ·····នៅក្នុងពេនមួយជិតនោះ មានជាងពីរបីនាក់ទៀត ចាំប្រឹងអារឈើធំៗទុកធ្វើជា·····សំរាប់ក្រាលផ្ទះ មានជាងពីរនាក់ទៀតអង្គុយលើជើងម៉ាកំពុងតែ·····ក្ដារទាំង········ដើម្បីនឹងឲ្យក្ដារនោះ·····ជាងខ្លះទៀតកាត់ឈើទាំង·····ជាបង្អួចទ្វារ ក្រុមជាងទាំងនេះធ្វើការដោយសេចក្ដីរីករាយសប្បាយ តាំងតែពីព្រឹកដល់ល្ងាចទើបឈប់ ។

---

មជ្ឈមដ្ឋានទី ១

## នព្វន្ត

ចំនួនពី ១០១ ដល់ ១.០០០

ដូចបាននិយាយមកហើយពីខែមុន យើងបង្រៀនចំនួននិ-មួយ ៗ ត្រូវបញ្ជាក់ចំនួននោះ ឲ្យសិស្សឃើញជាក់ស្ដែង ៗ ដូច្នេះគ្រូត្រូវប្រើបង្កើះ ៗ ក្នុងខែនេះត្រូវរៀនចំនួនពី ១០០ ដល់ ៩៩៩ មានលេខបីខ្ទង់ ។ ខ្ទង់ទី ៣ ខាងឆ្វេងខ្ទង់ដប់ គឺសំគាល់

បំនួនរយ ដូច្នេះរួមទាំង ៣ ខ្ទង់គេហៅពីស្តាំទៅឆ្វេងថា ខ្ទង់រាយ ខ្ទង់ដប់ ខ្ទង់រយ ។ ឯបង្កើះដែលយកមកបង្រៀនក៏ត្រូវឲ្យមាន ៣ បែបផ្សេងគ្នាដែរ គឺ ១ បែបសំរាប់ខ្ទង់រាយ មួយបែបសំរាប់ខ្ទង់ដប់ មួយបែបទៀតសំរាប់ខ្ទង់រយ ដាក់ក្នុងបំពង់ឬប្រអប់ផ្សេងគ្នាដែរ ។

## អាទិត្យទី ១

### ១— *បង្រៀនចំនួនពី ១០០ ដល់ ៣០០*

គ្រូធ្វើខ្លួនឯងឬប្រើសិស្សឲ្យយកបង្កើះដាក់ក្នុងប្រអប់ តាមបំនួនដែលគ្រូប្រាប់ ឧបមាដូចជាមួយរយម្ភៃប្រាំ (១២៥) សិស្សត្រូវយកបង្កើះក្រហម ១ ដែលសំគាល់បំនួនរយ ដាក់ក្នុងប្រអប់ខាងឆ្វេង

ខ្ទង់រយ ខ្ទង់ដប់ ខ្ទង់រាយ

ហើយយកបង្កើះ ៥ ទៀតដាក់ក្នុងប្រអប់ខាងស្តាំ ឯក្នុងប្រអប់ខ្ទង់ដប់កណ្តាលដាក់បង្កើះ ២ ផ្សេងទៀត ឲ្យសិស្សមើលបំនួនបង្កើះដែលដាក់ក្នុងប្រអប់ទាំង ៣ ថា មួយរយម្ភៃប្រាំ (១២៥) ។ គ្រូសរសេរបំនួន ១២៥ នេះនៅលើក្តារខៀន ។ សូមធ្វើដូច្នេះគ្រប់ៗបំនួនដែលគ្រូត្រូវបង្រៀន ។

សូមបញ្ជាក់សិស្សថា បើកាលណាគ្មានបំនួនដប់ឬបំនួនរាយក្នុងខ្ទង់ដប់ឬរាយទេ គេត្រូវសរសេរសូន្យ (០) ជំនួស ។

២– ហាត់មើលបំនួន

ឲ្យសិស្សមើលបំនួនដែលគ្រូបានសរសេរនៅក្ដារខៀន ១២៥-១០៣-២០៩-៣០០-២៥០ .......។ល។

៣– ហាត់រាប់បំនួន

ឲ្យរាប់ថែមបួនៗពី១០៤ ដល់ ១៤៨ រួចរាប់សាបុះមក ១០០ វិញឲ្យរាប់ថែមប្រាំៗ ពី ២០០ ដល់៣០០ រួចរាប់សាបុះពី ៣០០ មកដល់២០០វិញ ។

៤– ហាត់សរសេរបំនួននឹងក្ដារធ្នួន

ឲ្យសិស្សសរសេរលេខតាមសូត្រ ឧបមា : ១០៥-១០៩ ១០២-១២០-១៣៥-១៨០-២១៥-៣០០-២៧៦...។ល។

៥– ហាត់គិតមាត់ទទេ

ស្រូវ ១៥ ថាំង ថែមស្រូវ ៨ ថាំងទៀត ត្រូវជាស្រូវប៉ុន្មានថាំង ?

នឹងរកចំនួនស្រូវឲ្យឃើញ ត្រូវបង្ហាត់សិស្សឲ្យគិតថា ៥ហាំង នឹង ៨ហាំង ត្រូវជា ១៣ ហាំង ។ ១៣ ហាំងនឹង ១០ ហាំងត្រូវជា ២៣ ហាំង ។

ខ្ញុំមានប្រាក់ ១០៦ រៀល លក់បន្លែបានប្រាក់ ២០ រៀលទៀត តើខ្ញុំមានប្រាក់ទាំងអស់ប៉ុន្មានរៀល ។

ឈ្មួញម្នាក់យកមាន់ ១៣០ ទៅលក់ឯផ្សារ វាលក់អស់មាន់ ២៥ ហើយ តើឈ្មួញនោះនៅសល់មាន់ប៉ុន្មានទៀត ។ល។

## ការហាត់

### ១– ឲ្យសរសេរជាលេខ

មួយរយសាមសិបប្រាំពីរ ។ មួយរយកៅសិបបួនរៀល ។ ពីររយប្រាំមួយរៀល ។ ពីររយហាសិបបី ។ល។

### ២– បំណោទ

អ្នកស្រែម្នាក់ទិញនង្គ័ល ១ នឹងរនាស់ពីរ ថ្លៃទាំងអស់ ១០៥ រៀល រនាស់ ១ ថ្លៃវា ៣០ រៀល តើនង្គ័លថ្លៃប៉ុន្មានរៀល ។

ជាងឈើម្នាក់ទិញសំពត់ ២ ផាប់ ផាប់ទី ១ ប្រវែង ៣៨ ម៉ែត្រ ផាប់ទី ២ ប្រវែង ៤២ ម៉ែត្រ យកមកដេរអាវ ៨ សំរាប់

មួយសំរាប់អស់សំពត់ ៦ ម៉ែត្រ តើជាងនោះនៅសល់សំពត់ប៉ុន្មានម៉ែត្រទៀត "ល ។

## អាទិត្យទី ២

ចំនួន ៣០០ ដល់ ៦០០

### លេខបូកនឹងលេខសងមានត្រាទុក

សូមបង្រៀនចំនួនពី ៣០០ ដល់ ៦០០ តាមរបៀបដូចបានអធិប្បាយពីអាទិត្យទី ១ ស្រាប់ ។

### ១– លេខបូកមានត្រាទុក

អ្នកស្រែម្នាក់ទិញគោញី ១ ថ្លៃ ៨៩ រៀល កូនជ្រូក ១ ថ្លៃ ៤៥ រៀល ទាំងអស់ត្រូវជាថ្លៃប៉ុន្មាន ។

ប្រមូលថ្លៃគោនឹងថ្លៃជ្រូក គឺរកចំនួន ៨៩ ថែម ៤៥ រៀល ហៅថាបូកលេខ ។

លេខបូកគឺវិធីសំរាប់ប្រមូលចំនួនអ្វី ៗ ដូចគ្នា រួមមកធ្វើជាចំនួនមួយ ។ ចំនួនដែលបូកឃើញនេះហៅថាចំនួនសរុប ។ លេខសញ្ញាសំរាប់លេខបូក គឺគំនូសជើងក្អែកនេះ ( + ) ចំនួសពាក្យថាថែមទៀតឬផ្សំនឹងឬបូកនឹង ។ គំនូសផ្តេក ពី បណ្តោយគ្នានេះ ( = ) សំរាប់ជំនួសពាក្យថាត្រូវជា ។

ឈ្មួញម្នាក់ទិញគ្រាប់ពោតមួយកន្លែងបាន១៥៦បាវ មួយកន្លែងទៀតបាន ១៨៩ បាវ មួយកន្លែងទៀតបាន ៩៤ បាវ ។ តើឈ្មួញនោះ ទិញបានគ្រាប់ពោតប៉ុន្មានបាវទាំងអស់ ។

នឹងរកចំនួនបាវទាំងអស់នោះត្រូវបូក ១៥៦ បាវ នឹង ១៨៩ បាវ ហើយនឹង ៩៤ បាវ ។ ខំសរសេរចំនួនមួយក្រោមចំនួនមួយ ហើយខំថា ៦ នឹង ៩ ត្រូវជា ១៥ ប្រាំដណ្ដប់នឹង ៤ ត្រូវជា ១៩ ខំសរសេរ ៩ នៅក្រោមខ្ទង់រាយ ហើយត្រាទុក ១ មួយដែលត្រាទុកនឹង ៥ ត្រូវជា ៦ ប្រាំមួយ នឹង ៨ ត្រូវជា ១៤ បួនដណ្ដប់នឹង ៩ ត្រូវជា ២៣ ខំសរសេរ ៣ នៅក្រោមខ្ទង់ដប់ ហើយត្រាទុក ២ ។ ២ នឹង ១ ត្រូវជា ៣ បីនឹង ១ ត្រូវជា ៤ ខំសរសេរ ៤ នៅក្រោមខ្ទង់រយ ត្រូវជា ៤៣៩ បាវ ។

```
 ១៥៦
+១៨៩
  ៩៤
─────
 ៤៣៩
```

ត្រូវប្រាប់សិស្សឲ្យយល់ប្រាកដថា កាលបូកខ្ទង់រាយខាងស្ដាំឃើញបាន ១៩ ហេតុម្ដេចក៏យើងសរសេរ តែ ៩ ហើយត្រាទុក ១ ។ ពីព្រោះក្នុង ១៩ មានរាយតែ៩ មានដប់មួយផង ឯដប់មួយផងនេះ ត្រូវយកទៅបញ្ចូលក្នុងខ្ទង់ដប់ ដូចគ្នាទើបបាន ។

ត្រូវចាំថានឹងធ្វើលេខបូក ៖ ១– គេសរសេរចំនួនមួយក្រោមចំនួនមួយជាជាប ហើយឲ្យចំខ្ទង់គ្នាផង គឺខ្ទង់រាយក្រោមខ្ទង់រាយ-ដប់ក្រោមខ្ទង់ដប់ – រយក្រោមខ្ទង់រយរៀង ៗ តទៅ ។

២– កាលណាគេសរសេររួចហើយ គេគូសបន្ទាត់មួយខណ្ឌពីក្រោម ។ ៣– គេតាំងបាប់បូកពីស្តាំហើយសរសេរចំនួនដែលបូកឃើញដាក់ពីក្រោមជួរលេខដែលបូក ។

## ត្រាទុក

បើចំនួនដែលបូកក្នុងមួយជួរៗ ដល់ឬលើសពី ១០ គេសរសេរតែចំនួនរាយ ហើយនឹងយកចំនួនដប់ទៅថែមក្នុងជួរខ្ទង់ដប់ខាងឆ្វេងទៀត ឯលេខត្រាទុកនឹងភ្លេចពុំបានទេ នៅក្រោមជួរខាងឆ្វេងបង្អស់នោះ បើបូកឃើញប៉ុន្មានគេសរសេរប៉ុណ្ណោះ ។

ការហាត់ ។– *បូកធ្វើលេខខាងក្រោមនេះ*

១៤៧ + ៦៤ = .... ៦៥ + ១៩៣ = ។ ៧២ + ៣៨+ ១០៩ = ។ ១៣៨ + ៥២ + ៩២ = ២០៦ + ២៧ + ៣៨ = ។ល។

## បំណោទ

១– អកជំនួញម្នាក់បានលក់ក្ការជើងមួយថ្លៃ ១៥០ រៀល

ទូមួយថ្លៃ ២០៦ រៀល ទូបាតមួយថ្លៃ ១២៩ រៀល តើអ្នកជំនួញបានចំណេញទាំងអស់ប៉ុន្មាន បើរបស់ទាំងបីនេះ ទិញមកថ្លៃ ៤២៣ រៀល ។

២– កូនសិស្សពីរនាក់ ម្នាក់មានគ្រាប់ឃ្លី ១៨ ម្នាក់ទៀតមាន ៤២ បើជាអ្នកមុននោះលេងឈ្នះ អ្នកក្រោយនោះគ្រាប់ឃ្លី ១៧ តើម្នាក់ៗមានប៉ុន្មាន ។ ទាំងពីរនាក់តើមានប៉ុន្មាន ។

៣– ជាងកាត់អាវម្នាក់មានសំពត់ ៤ ផាប់ មួយផាប់ប្រវែង ៣៦ ម៉ែត្រ ឯផាប់ឯទៀតៗ ប្រវែង ៩ ម៉ែត្រ តើជាងកាត់អាវនោះ មានសំពត់ប៉ុន្មានម៉ែត្រ ។

អាទិត្យក្រោយ ចំនួនពី ៦០០ ដល់ ៩៩៩ សំធ្វើជួបមុនៗ

---

មធ្យមដ្ឋានទី ១

## រង្វាស់រង្វាល់

អាទិត្យទី ១.– *អំពីដេកាម៉ែត្រ ហិកតូម៉ែត្រ គីឡូម៉ែត្រ សុំលោកគ្រូរកម៉ែត្រ ១ ដេកាម៉ែត្រ ដេកាម៉ែត្រសំពត់ ដេកាម៉ែត្រសំប៉ែតដែក*

របៀបបង្រៀន.— សុំឲ្យយកម៉ែត្រវាស់បញ្ជាក់ប្រវែងដេកាម៉ែត្រ ឲ្យសិស្សសង្កេតមើល ក្រែងស្គាល់ប្រយោជន៍អ្វី ។ សុំឲ្យបញ្ជាក់សិស្សឲ្យប្រាកដនៃមេរៀន អំពីដេកាម៉ែត្រ ពាក្យដេកា មានន័យថាច្រើនដង ១០ដង

ការហាត់វាស់: ឲ្យសិស្សស្មានប្រវែងទីធ្លាសាលា ឬផ្លូវថ្នល់ រួចឲ្យយកដេកាម៉ែត្រមកវាស់បញ្ជាក់

ការហាត់គិត: ឲ្យសិស្សរកក្នុង ៥ដេកាម៉ែត្រ មានប៉ុន្មានម៉ែត្រ ក្នុង ២៩ដ, មានប៉ុន្មានម៉ែត្រ ៧ដាម៣ ត្រូវជាប៉ុន្មានម៉ែត្រ ៣៦ម, ត្រូវជាប៉ុន្មានដេកាម៉ែត្រ ។ល។

ការហាត់សរសេរ.— ជាងដេរម្នាក់ទិញសំពត់មួយ ១២ម, មួយទៀត ៦ម, អ្នកនោះទិញសំពត់ទាំងអស់..... ម៉ែត្រ គេយក ២ដេកាម៉ែត្រមកកាត់ជាសម្លៀកបំពាក់ ជាងនោះនៅសល់សំពត់ ....ម៉ែត្រទៀត ។

## អំពីហិកតូម៉ែត្រនិងគីឡូម៉ែត្រ

សុំយកដេកាម៉ែត្រមកឲ្យសិស្សមើល ហើយប្រាប់ថារង្វាស់ហិកតូម៉ែត្រនេះគ្មានរូបទេ ត្រូវតែជាគោលសំគាល់ប្រវែង ១០០ម, ក្នុង ១ ហិកតូម៉ែត្រ មាន ១០ ដេកាម៉ែត្រត្រូវជា ១០០ម, ។

គីឡូម៉ែត្រ.— ខ្នាតនេះជាគោលសំរាប់សំគាល់ប្រវែងផ្លូវថ្នល់ ទន្លេ ព្រែក ស្ទឹង ។ល។

ការហាត់គិត៖ ឲ្យសិស្សបំបែកគីឡូម៉ែត្រ ទៅជាហិកតូម៉ែត្រ ជាដេកាម៉ែត្រ រួចផ្ទុយទៅវិញ ដូចជាក្នុង ៤ គ.ម មានប៉ុន្មានដេកាម៉ែត្រ ប៉ុន្មានហិកតូម៉ែត្រ ? ប៉ុន្មានម៉ែត្រ ? ៣១៧៩ ម. ត្រូវជាប៉ុន្មានគីឡូម៉ែត្រ ប៉ុន្មានហិកតូម៉ែត្រ ប៉ុន្មានដេកាម៉ែត្រ

ការហាត់សរសេរ កាលថ្ងៃអ្នកបែកសំបុត្រ ត្រូវដើរចម្ងាយ ១៤ គ.ម អ្នកនោះបានដើរ ៩.៨១០ម តើនៅដើរប៉ុន្មានហិកតូម៉ែត្រ ប៉ុន្មានគីឡូម៉ែត្រទៀត

សេចក្ដីរំលឹក.— សុំលោកគ្រូបញ្ជាក់សិស្ស បង្ហឹកវាឲ្យស្គាល់ពាក្យ ដេកា ហិកតូ គីឡូ

អាទិត្យទី ២.— អំពីដេកាលីត្រ ហិកតូលីត្រ

អាទិត្យទី ៣.— អំពីដេកាក្រាម ហិកតូក្រាម គីឡូក្រាម

អាទិត្យទី ៤.— សារៀនវិជ្ជាតាំងពីដើមខែឡើងវិញ ឲ្យសិស្សហាត់គល់ ជួន វគ្គផ្សេង ៗ

## ធរណីមាណសាស្ត្រ

អាទិត្យទី ១.— អំពីលក្ខណៈនៃបន្ទាត់តាំងឡាយ... សុំសាកសួរអំពីមេរៀនខែមុន ៗ

អាទិត្យទី ២.— អំពីផ្ទៃបួនជ្រុងស្មើ

**របៀបបង្រៀន.—** គូរផ្ទៃបួនជ្រុងស្មើមួយនៅក្ដារខ្មៀន ឲ្យសិស្សវាស់ជ្រុងទាំងបួន តើដូចម្ដេច (ស្មើគ្នា) ចុះមុមទាំងបួនជាមុមអ្វី ។ រួចឲ្យរកន័យរបស់អ្វីខ្លះដែលមានរាងបួនជ្រុងស្មើ ឲ្យរកឲ្យបានច្រើន ។

**អំពីបរិវេណនៃផ្ទៃបួនជ្រុងស្មើ.—** វិធីនេះមិនត្រូវប្រាប់ន័យសិស្សទេ គឺត្រូវណែនាំឲ្យរកថា គំនូរបួនជ្រុងស្មើនេះ មួយជ្រុងប្រវែង ៣ ដេស៊ីម៉ែត្រ តើបរិវេណប៉ុន្មាន ។ ឯនេះធ្វើម្ដេចឲ្យឃើញ ១២ ដេស៊ីម៉ែត្រ ឲ្យសិស្សរកន័យនឹងគិតបរិវេណនៃផ្ទៃ៤ជ្រុងស្មើ តើធ្វើដូចម្ដេច ។

**ការហាត់គិត.—** សួនមួយរាងបួនជ្រុងស្មើ មួយជ្រុងប្រវែង ៥ម. តើបរិវេណប៉ុន្មាន ។ បរិវេណស្រែបួនជ្រុងស្មើមួយមាន ២៨ម. តើស្រែនោះមួយជ្រុងប្រវែងប៉ុន្មាន ។ ល ។

**ការបកសរសេរ.—** សុំជ្រើសរើសឲ្យសិស្សធ្វើផងចុះ

---

មជ្ឈមដ្ឋានទី ២

## រង្វាស់រង្វាល់

**អាទិត្យទី ១.—** អំពីម៉ែត្រ.... (ម៉)

សុំរកម៉ែត្រគ្រប់មុខមកឲ្យសិស្សកាន់វាស់ ម៉ែត្រឈើ ៥ កំណាត់ ១០ កំណាត់ ម៉ែត្រឈើត្រង់ស្គានជាបន្ទាត់ ម៉ែត្រសំពត់ដែលជាងដេរ ម៉ែត្រដែកជាងធ្វើម៉ាស៊ីន ។

របៀបប្រើ.— ម៉ែត្រជាខ្នាតប្រមាណនៃរង្វាស់ប្រវែង គេសរសេរកាត់ (ម៉).— ឲ្យសិស្សរកផលប្រយោជន៍នៃម៉ែត្រនិមួយ ៗ ហើយនឹងអ្នកដែលត្រូវការម៉ែត្រទាំងនោះ ។

ការហាត់ធ្វើ.— ឲ្យសិស្សស្ទាបបណ្ដោយ ទទឹងក្ដារខៀន រួចឲ្យវាស់ផ្ទៀងផ្ទាត់ ។

ការហាត់គិតមាត់ទទេ.— បំការមួយបួនជ្រុងស្មើ មួយជ្រុងប្រវែង ១៥ ម៉ែត្រ តើជុំវិញបំការនោះមានប៉ុន្មានម៉ែត្រ ។ អ្នកលក់ព្រែម្នាក់មានព្រែ ១ កីប្រវែង ១៣ ម៉, ថ្លៃមួយម៉ែត្រ ២០ រ, តើព្រែនោះថ្លៃប៉ុន្មាន ។ (ល)

ការហាត់សរសេរ.— ខ្សែលួសមួយម៉ែត្រទម្ងន់ ៨០ ក្រាម តើខ្សែលួស ៧២.០០០ ក្រាម ប្រវែងប៉ុន្មានម៉ែត្រ ។

អាទិត្យទី ២.— ប្រវែងដែលធំជាងម៉ែត្រ ខ្នាតដែលតូចជាងម៉ែត្រ ។

សុំមើលសៀវភៅក្បួននព្វន្ត “ព្រាស្ស” បរិបុណ្ណផ្នែកទំព័រ ១៧

ការហាត់សុំត្រូវជ្រើសរើសតាមចិត្តចុះ

អាទិត្យទី ៣ .— ខ្នាតប្រវែងដែលតាមកាន់វាស់បាន សុំមើលសៀវភៅដែលទំព័រ ១៦

បើគេបានឲ្យគេខ្នាតទាំងនោះមកបង្ហាញឲ្យឃើញផង

អាទិត្យទី ៤.— សារៀនវិជ្ជាដែលបានបង្ហាញពីដើមខែឡើងវិញ សុំហ្វឹកហ្វឺនសិស្សឲ្យថ្នឹកក្នុងការគិតគូបចំនួនមួយទៅមួយ ៗ

## ធរណីមាណសាស្ត្រ

អាទិត្យទី ១.— អំពីត្រីកោណ

របៀបបង្រៀន.— សុំលោកគ្រូឲ្យសិស្សរកន័យ ដោយរាប់ជ្រុង ដោយសង្កេតមើលមុម ៗ

អំពីរាងត្រីកោណទាំងឡាយ: ក) មិនស្មើជ្រុង ខ) ស្មើជ្រុងពីរ គ) ស្មើជ្រុងទាំងបី ឃ) កងជាស្វាបគ្នា ៗ

ឲ្យគេរបស់អ្វី ដែលមានរាងត្រីកោណ

អាទិត្យទី ២.— អំពីបរិវេណនៃត្រីកោណ

ដូចបានអធិប្បាយក្នុងអាទិត្យទីមួយ ត្រូវឲ្យសិស្សរកន័យបរិវេណត្រីកោណនិមួយ ៗ ៗ មិនស្មើជ្រុងត្រូវធ្វើដូចម្ដេច ត្រីកោណស្មើជ្រុងពីរ ធ្វើដូចម្ដេច ស្មើជ្រុងទាំងបីត្រូវធ្វើដូចម្ដេច កងស្វាយគ្នាធ្វើដូចម្ដេច ៗ

ការហាត់.— សុំមើលសៀវភៅក្បួនទត្ថ សំរាប់ថ្នាក់មធ្យមដ្ឋាន ទី ១ ទំព័រលេខ ៦៣

ការហាត់សរសេរ.— ចំការមួយរាងត្រីកោណ ស្មើជ្រុងពីរជុំវិញប្រវែង ៦៤ ម៉ែត្រ ចូរគិតឲ្យឃើញប្រវែងជ្រុងដែលស្មើគ្នានិមួយ បើជ្រុងដែលមិនស្មើប្រវែង ៩ ម. ។

អាទិត្យទី ៣.— រកផ្ទៃក្រឡានៃត្រីកោណ

មុននឹងបង្រៀនវិធីនេះ សុំធ្វើឲ្យសិស្សឃើញថា ត្រីកោណ ត្រូវជាពាក់កណ្ដាលបួនជ្រុងញាយស្រប ហេតុនេះនឹងរកផ្ទៃក្រឡាត្រីកោណ ត្រូវយកបាតទៅគុណនឹងកំពស់ រួចចែកជាពីរ ឬយកបាតទៅគុណនឹងពាក់កណ្ដាលកំពស់ ឬយកពាក់កណ្ដាលបាតទៅគុណនឹងកំពស់ ក៏ឃើញចម្លើយដូចគ្នា ។

ការហាត់គិត.— សុំលោកគ្រូតែងពាក្យចោទសួរចុះ ។

ការហាត់សរសេរ.— ចំការមួយរាងត្រីកោណស្វាបក្ដាន ជ្រុងមុមកែងប្រវែង ៦៨ ម. នឹង ៨៧ ម. ៥០ ចូររកថ្លៃដីនោះ បើមួយម៉ែត្រក្រឡាថ្លៃ ៤៥ រៀល ។

អាទិត្យទី ៤.— សារៀនវត្ថុទាំងអស់ដែលបានបង្ហាញ ហើយសុំបញ្ជាក់ឲ្យច្បាស់កន្លែងណាដែលសិស្សមិនទាន់យល់ប្រាកដ ។

សេចក្ដីរំឭក.— បើធ្វើបានឲ្យបង្រៀនរកបាតកំពស់ ។

សុំឲ្យហាត់គិតនៅលើក្ដារដ្ឋនឲ្យបានបរិបូណ៌

អាទិកដ្ឋាន

## នព្វន្ត

អាទិត្យទី ១.– ចំនួនពីមួយរយទៅដល់មួយពាន់

(មើលក្នុងក្បួននព្វន្តអាទិកដ្ឋានទំព័រ ៥៣ – ៥៤)

អំពីខ្ទង់រយ ខ្ទង់ដប់ ខ្ទង់រាយ ។

(មើលក្នុងសៀវភៅដដែលទំព័រ ៥៤ – ៥៥)

### វិធីហាត់គិតមាត់ទទេ

ឲ្យសិស្សរៀនរាប់

១.– ពី៩៩ ដល់ ២០០ ។ ពី ២០០ ដល់ ៣០០ ។

២.– រាប់ដប់ៗ ពី ១០ ដល់ ១០០, ២០០, ៣០០ ។ល។

៣.– រាប់ម្ភៃៗ ពីម្ភៃដល់ ១០០០, ពី ១០០០ ថយមកម្ភៃ ។

### វិធីហាត់សរសេរ

៧៨ម + ៩៤ម + ១៥២ម = .... ។ ៦៣១ម + ៩៧ម = ... ។

៩៧៨រ – ៧៥៧រ = . . . ។ ៧២៨រ – ៣២៧រ = ..... ។

អាទិត្យទី ២.– ចំនួនពីមួយៗ ឡើងទៅខ្ទង់ពាន់

(មើលក្នុងសៀវភៅក្បួននព្វន្តដែលទំព័រទី៥៥)

អាទិត្យទី ៣.– ចំនួនពីមួយៗ ឡើងទៅ

(មើលក្នុងក្បួននព្វន្តដែលទំព័រ៥៦–៥៧)

អាទិត្យទី ៤.– រកថ្លៃដើមរបស់មួយ ដែលហៅថាថ្លៃដើមនោះគឺចំនួនប្រាក់ដែលគេបញ្ចេញទិញអីវ៉ាន់ ជួនកាលមានថែមទាំងសោហ៊ុយដឹកនាំអីវ៉ាន់ទៅលើថ្លៃដែលទិញនោះផង ។

បំណោទ

ស្រីម្នាក់លក់ក្រែព ៣៨ម,៥០ ថ្លៃ ៥រៀលក្នុងមួយម៉ែត្រ ហើយចំណេញបានទាំងអស់ ១០៛, គេសួរថាតើថ្លៃដើមទាំងអស់ប៉ុន្មាន ។ ក្នុងមួយម៉ែត្រប៉ុន្មាន ។

**រង្វាស់រង្វាល់**

អាទិត្យទី ១.– អំពីក្រាម

ក្រាមសំរាប់ថ្លឹងទម្ងន់វត្ថុតូច (មើលក្នុងក្បួននព្វន្តអាចកដ្ឋានទំព័រទី២២) ។ សូមយកជញ្ជីងនិងក្រាមមកឱ្យសិស្សរៀនថ្លឹងវត្ថុស្រាល គឺស្បែកលប់ ស្លាបប៉ាក្កា ។ល។

អាទិត្យទី២.— អំពីដេកាក្រាម

*(មើលតាមក្បួនឧត្តមដែលទំព័រ ៣៦ – ៣៧)*

*ហើយដាក់វិធីហាត់សរសេរឲ្យសិស្សធ្វើផង*

អាទិត្យទី ៣.— *ដេសីម៉ែត្រ សង់ទីម៉ែត្រមីលីម៉ែត្រ*

*(សុំមើលតាមសៀវភៅដែលទំព័រទី ៦៩ – ៧០)*

អាទិត្យទី ៤.— *អំពីរង្វាស់រង្វាល់ខ្មែរ*

*(មើលតាមសៀវភៅដែលទំព័រទី ១១០)*

*សូមតែងចំណោទតាមសេចក្តីដែលដាក់ឲ្យសិស្សរៀននោះផងចុះ*

---

បរិច្ឆណាដ្ឋាន

## ១ – រង្វាស់រង្វាល់

## អំពីដេកាម៉ែត្រ - ដេកាលីត្រ - ដេកាក្រាម

*សូមមើលសៀវភៅក្បួនឧត្តមបរិច្ឆណដ្ឋានទំព័រ ៧៣*

វិធីហាត់គិតមាត់ទទេ-សរសេរហើយនិងចំណោទមានបរិបូណ៌ហើយ ៗ សូមលោកគ្រូធ្វើដូចធម្មតា គឺបង្រៀនវាស់ បង្រៀនវាល់ បង្រៀនថ្លឹង ឱ្យសិស្សចេះវាស់ វាល់ថ្លឹង ហើយចំណាំដេកាម៉ែត្រ ដេកាលីត្រ ដេកាក្រាមនោះឱ្យប្រាកដ ឱ្យវាដឹងថា: ដេកាម៉ែត្រ

មានខ្សែលួសប្រវែង ១០ ម៉ែត្រជារបស់សំរាប់សំគាល់ ។ ដេកាក្រាម មានកូនជញ្ជីង ឬ ភ្នែកជញ្ជីង (តាមភាពជញ្ជីង) ជារបស់សំរាប់សំគាល់ ។

ដេកាលីត្រមានរង្វាល់បំណុះ ១០ លីត្រជាសំគាល់ ៗ រួចហើយ សូមបង្រៀនគិតលេខឬបំណោទដូចបានពន្យល់ពីមុនៗ មកស្រាប់។

២ – ដេកាលីត្រ - ដេកាក្រាម

សូមមើលក្នុងសៀវភៅក្បួនតូចបរិបូណ៌ជ្ជាន ទំព័រ ៣៣ ហើយសូមបង្ហាត់ឲ្យវាល់ - ឲ្យថ្លឹងរបស់ផ្សេង ៗ ឲ្យបំណាំដេកាលីត្រ ហើយនឹងដេកាក្រាមឲ្យច្បាស់ ។

វិធីហាត់គិតមាត់ទទេ សូមធ្វើតាមក្បួននេះនៅទំព័រ ៣៣ ដដែល ហើយសូមបំបែកការហាត់ឲ្យច្រើនទៅទៀត ឲ្យមានលេខ បូក - សង - គុណ : ឧបមាដូចជា ធុងមួយមានស្រាទំពាំងជូរ ៧ ដេកាលីត្រ ធុង ១ ទៀតមាន ៣ ដេកាលីត្រ - មានស្រាប៉ុន្មានដេកាលីត្រ ។ ល ។

បំណាំ - សូមនាំគិតពីដេកាក្រាមរបៀបដូចគ្នា ។ ធ្វើលេខ-បំណោទ សូមឲ្យធ្វើលេខ - បំណោទរបៀបដូចខាងក្រោមនេះ

| | | | |
|---|---|---|---|
| ២៨ល. | ១៦ក្រ. | ៤៩ល. | ១៥ក្រ. |
| + ១៧ | + ១៩ | − ២៧ | × ៣ |
| ៤០ | ១៣ | | |

១ – គេវាល់អង្ករ ៤ បាវ ១ បាវមាន ១៤ ដេកាលីត្រនឹង ៥ លីត្រ ១ បាវទៀតមាន ១៣ ដា.ល. នឹង ៦ ល. ១ បាវទៀត ១១ ដា.ល. នឹង ៧ ល. ។ តើទាំងអស់មានអង្ករប៉ុន្មានដេកាលីត្រ នឹងលីត្រ ។

២– ម្ដាយខ្ញុំថ្លឹងសាច់ជ្រូក ៧ ដុំ ។ ១ ដុំមាន ៧ ដេកាក្រាម នឹង ៨ ក្រាម ១ ដុំទៀតមាន ៨ ដេកាក្រាមនឹង ៦ ក្រាម ១ ដុំទៀតមាន ១០ ដា.ក្រ. នឹង ៨ ក្រ. ។ តើទាំងអស់មានទម្ងន់ប៉ុន្មាន ។ល។

### ៣ – រង្វាស់រង្វាល់

សាបង្រៀនពីដេកាម៉ែត្រឡើងវិញ (ដា.ម.) សូមបង្វឹកសិស្ស ឲ្យចាំច្បាស់ប្រាកដពីដេកាម៉ែត្រ · និងប្រដាប់ដែលត្រូវបង្រៀនក្នុងពេលនោះ ។

ប្រដាប់ ដេកាម៉ែត្រមួយ (ប្រវាក់ខ្សែសិនឬយកខ្សែមួយមកវាស់ធ្វើ) ម៉ែត្រមួយៗ ឲ្យវាស់បញ្ជាក់ប្រវែងដេកាម៉ែត្រជាមួយនឹងម៉ែត្រ (ឃើញថាក្នុង ១ ដេកាម៉ែត្រមាន ១០ ម៉ែត្រ គេសរសេរ ១ ដា.ម )។ ជួប្រេះចំនួនដេកាម៉ែត្រសរសេរដាក់នៅខ្វង់ដប់ ។

ឲ្យហាត់សរសេរកាត់ចំនួន ២.៥.៦.៣.៨.៤ ដេកាម៉ែត្ររួចឲ្យសរសេរបំបែកទៅជាម៉ែត្រ ព្រមទាំងមើលឋាផង ។

ឲ្យហាត់វាស់បញ្ជាក់ប្រមាណប្រវែងទីធ្លា បណ្ដោយសាលារៀន ។ល។ នឹងដេកាម៉ែត្រ ។

## ហាត់គិតមាត់ទទេឆ្លើយនៅក្ដារខ្នន

១១– ត្រូវជាប៉ុន្មានម៉ែត្រក្នុង ៣ ដា.ម. ។ ៨ ដា.ម. ។ ៥ដា.ម. ។ ៣ដា.ម. ។ ៤ដា.ម. ។ ៦ដា.ម. នឹង ៣ម. ។ ៧ដា.ម. នឹង ៩ម. ។

១២– ត្រូវជាប៉ុន្មានដេកាម៉ែត្រក្នុង ២០-៤០-៦០-៨០ម.

១៣– ត្រូវជាប៉ុន្មានដេកាម៉ែត្រក្នុង ២៧ម. ។ ៥៦ម. ។ ៩៣ម. ។ ៣៨ម. ។ល។

កុមារដ្ឋាន

## នព្វន្ត

### ចំនួនពី ១០ ដល់ ២០

*លេខបូក - លេខសង - ខ្ទង់ដប់ - ខ្ទង់រាយ*

ចំនួន ១០.— បង្កើះប្រាំបួន នឹងបង្កើះមួយត្រូវជាបង្កើះដប់ ។ ខ្ញុំគូសបង្កើះដប់........................ IIIIIIIII

ប្រាំបួននឹងមួយ ឬមួយនឹងប្រាំបួនត្រូវជាដប់ ខ្ញុំសរ-សេរចំនួនដប់ គឺខ្ញុំសរសេរលេខ ១ ហើយនឹងលេខ ០........១០ ខ្ញុំសរសេរសំគាល់ចំនួនដោយសារលេខ ។ លេខមានតែដប់ទេ គឺៈ ១, ២, ៣, ៤, ៥, ៦, ៧, ៨, ៩, ០. ។ ចំនួន និមួយ ៗ សរសេរតែលេខៈ១ ខ្ទង់ទេ គេហៅថាខ្ទង់រាយ ឯចំនួនដប់ត្រូវសរសេរលេខៈ២ ខ្ទង់ហៅថាខ្ទង់ដប់ ។

*ការហាត់មាត់ទទេ និងហាត់សរសេរ*

ឲ្យសិស្សរាប់បង្កើះនឹងគិតលេខខាងក្រោមនេះ =

កៅអី ៨ នឹងកៅអី ២ ត្រូវជា.............. ។
ក្តារខៀន ១០ ដកក្តារខៀន ២ បេញនៅសល់... ។
៦ នឹង ៤ ត្រូវជា.... ។ ៨ នឹង ២ ត្រូវជា...... ។
៥ នឹង ៣ ត្រូវជា.... ។ ២ នឹង ៧ ត្រូវជា...... ។

ចំនួន ១១.— បង្កើះដប់ នឹងបង្កើះមួយ ត្រូវជាបង្កើះដប់មួយ ។
ដប់មួយ គឺមានខ្ទង់ដប់ ១ នឹងខ្ទង់រាយ

១.......................................១១

ក្នុងចំនួនដែលមានលេខច្រើនខ្ទង់, លេខខ្ទង់រាយនៅខាងស្តាំ, លេខខ្ទង់ដប់នៅខាងឆ្វេង, ជិតខ្ទង់រាយ

*ការហាត់មាត់ទទេ នឹងហាត់សរសេរ.—*

ឲ្យសិស្សរាប់បង្កើះ ៨ នឹង ៣....; ៥ នឹង ៦.... ។
១១ ដក ៨...........; ១១ ដក ៦ ........... ។
៤ នឹង ៥............; ៦ នឹង ១ ............ ។

ចំបែកបង្កើះ ចំនួន ១១ ជា ២ បាច់ = ចំបានបង្កើះ ១ បាច់ ១០ នឹង ១; ឬ ១ បាច់ ៩ នឹង ១ បាច់ ២; ឬ ១ បាច់ ៨ នឹង ១ បាច់ ៣; ឬ ១ បាច់ ៧ នឹង ១ បាច់ ៤ ។

ចំនួន ១២, ១៣, ១៤, ១៥, ១៦, ១៧, ១៨, ១៩

## របៀបបង្រៀនដូចគ្នា

ចំណោទ

១)– ក្នុងកញ្ច្រែងមួយមានពង ១៣ ។ បែកអស់ ៤ ។ នៅសល់ពង.......ទៀត ។

២)– ក្នុងកន្លែងរៀនមួយ មានកូនសិស្ស ១៦ នាក់ មានកូនសិស្ស ៣ នាក់ ឈឺពុំបានមករៀន នៅសល់កូនសិស្ស....នាក់មករៀន ។

៣)– ខ្ញុំទិញសំពត់ពីរកំ ។ កំមួយមានប្រវែង ៥ម៉, កំមួយទៀត ៦ ម៉, ។ ខ្ញុំទិញសំពត់ទាំងអស់...ម៉ែត្រ

(សូមគ្រូរកចំណោទ ឲ្យបានច្រើនយកមកឲ្យសិស្សធ្វើឲ្យយល់ឲ្យច្បាស់ ពីចំនួន ១០ ដល់ ២០·)

---

កុមារដ្ឋាន

### រង្វាស់រង្វាល់

ម៉ែត្រ (ត)

ម៉ែត្រគ្រប់បែបៈ ម៉ែត្របត់, ម៉ែត្រត្រង់, ម៉ែត្រសំពត់,

(សូមបង្រៀនរបៀបដូចខែមុន តែសូមបង្រៀនសិស្សឲ្យប្រសប់វាស់របស់អ្វី ១ ទាំងពួង)

អានិកដ្ឋាន

## វិត្ថុស្ធាឲ្យាយន៍

### មេរៀនទី ១ — សត្វបំរើ - ឆ្មា

*ប្រដាប់ក្នុងគមកបង្រៀន.—* ឲ្យយករូបសត្វផ្សេងៗ មកឲ្យសិស្សមើល បើគ្មានឲ្យគូររូបសត្វបំរើ ដូចជាឆ្មាជាដើម នៅក្ដារខៀន ។

សត្វបរិភោគ ហើយដកដង្ហើមដូចយើង - ពិនិត្យមើលមាត់និងច្រមុះឆ្មា វាស៊ីអ្វី? បាយ សាច់ ត្រី នំ ។

សត្វបំរើឯទៀតស៊ីអ្វី? គោ, ក្របី, សេះស៊ីស្មៅ, បំពង, គ្រាប់, ។ ជ្រូក ស៊ីគ្រប់វត្ថុ និងលាមកផង ។

*ពិនិត្យមើលខ្លួនឆ្មា, ក្បាល, ជើង, ក្រចក, រោម*

នាំសិស្សរំពឹងទៅក្នុងខ្លួនឆ្មា: មានក្រពះបាយ ពោះវៀនសំរាប់រំលាយអាហារដែលស៊ីទៅតាមមាត់ ដែលធ្មេញកិនឲ្យខ្ទេច ។ មានបេះដូងនិងឈាម ហើយនិងសរសៃសំរាប់ឈាមរត់ ហើយមានសួតសំរាប់ដកដង្ហើមដូចយើងដែរ ។

*ធៀបប្រៀបឆ្មាទៅនឹងឆ្កែ និងខ្លា ។ល។*

ផលប្រយោជន៍ដែលបានពីសត្វ-ឆ្មាចាប់កណ្ដុរ ។ ឆ្កែចាំផ្ទះ ហើយតាមម្ចាស់ទៅព្រៃ ។ គោ, ក្របី អូសរទេះ ទាញនង្គ័ល ។ សេះសំរាប់ជិះនិងអូសរទេះ ។ល។

*មេរៀន* – ឆ្មាជាសត្វជើងបួន (ចតុប្បាទ) ខ្លួនវែងមានស្បែកគ្របជិត ហើយមានរោមទន់ ។ ក្បាលវាមូល មានពុកមាត់វែង ។ ជើងវាមានម្រាមប្រាំ ខាងចុងមានក្រចក ។ វាលាក្រញាំក្រចក កាលណាវាចាប់កណ្ដុរយកមកទះសម្លាប់ ។ ឆ្មាលោតបានឆ្ងាយហើយប្រសប់ឡើងណាស់ ។ ធ្មេញវាតូចៗស្រួចហើយមុតណាស់ ឆ្មាស៊ីសាច់ឆៅដែរ ។

*ក្នុងព្រៃមានឆ្មាព្រៃ, ខ្លាដែលដូចជាឆ្មាដែរ*

---

ពាក្យសួរ.— ចូរនិយាយពីឆ្មា ក្បាលវា, រោមវា, ជើងវា, ធ្មេញវាដូចម្ដេច ។ ព្រោះអ្វីបានជាក្រចកឆ្មាស្រួចជាងក្រចកឆ្កែ ។ ក្រចកវាសំរាប់ធ្វើអ្វី ។ សត្វអ្វីខ្លះដែលដូចជាឆ្មា ។

*សេចក្ដីពិនិត្យថែមទៀតក្រៅពេលរៀន*

ឲ្យសិស្សពិនិត្យឆ្មាតាមចាប់កណ្ដុរ ចាប់ចាប ។ ឲ្យពិនិត្យភ្នែកវាក្នុងពេលថ្ងៃ និងក្នុងពេលងងឹត ។ សង្កេតមើលកិរិយាឆ្មាកាលណាវាចាប់សត្វបាន ។

មេរៀនទី ២.– សត្វស្លាបស្រុក-មាន់

ធ្វើដូចរបៀបពីមុន គឺយកសត្វស្លាប ឬរូបសត្វស្លាប មកឲ្យសិស្សពិនិត្យ ក្បាល ភ្នែក ចំពុះ-ទំហំខ្លួន-ស្លាប-ជើង-កន្ទុយក្រញាំជើង-ពង (ស៊ុត) ធៀបប្រៀបពងមាន់នឹងពងទា-សង្កេតមើលវាខុសគ្នានឹងអ្វីខ្លះ (ទំហំ-ទំងន់) – សង្កេតមើលសំបកពង-ពងក្រហម-ពងស ។ វាដើរដូចម្តេច ។ វាហើរ-វាទំ-វាស៊ីអ្វីខ្លះ។

បើរកបានឲ្យយកមាន់ងាប់ទាំងមូលមកវះមើល ក្នុងខ្លួនវាពិនិត្យមើលពោះវៀន-ក្រពះ-បេះដូង-ក្រពះ- សួត ។ល។

*ត្រៀមពីនេះឲ្យធ្វើតាមរបៀបទី ១ ចុះ*

## វិធីបង្ការរោគ

ដំបូងរំឭកសិស្សអំពីផលប្រយោជន៍នៃការសំអាត ដូចមានក្នុងទស្សនាវដ្តីខែមុនស្រាប់ ។

បន្ទាប់មកពន្យល់សិស្សថា ការសំអាតខ្លួន-សម្លៀកបំពាក់នឹងចំណីអាហារ នោះមិនទាន់គ្រប់គ្រាន់ទេ ត្រូវសំអាតផ្ទះសម្បែងនឹងកន្លែងអង្គុយ-ដេកផង ព្រោះខ្លួនអ្នកស្អាតហើយ ប៉ុន្តែអ្នកអង្គុយឬដេកលើកន្លែងមិនស្អាត អ្នកនឹងទទួលឆ្លងរោគពីគេដែរ ។

## មេរៀនទី ១.– ការសំអាតផ្ទះសម្បែង

ត្រូវបោសផ្ទះរាល់ថ្ងៃ ។ មុនបោសត្រូវប្រោះទឹកក្ការ ឬអំផ្លូ ក្រាល កុំឲ្យធូលីហុយទៅជាប់ជញ្ជាំង ឬវត្ថុនានា ។ ត្រូវយកសំពត់ជ្រលក់ទឹកសាប៊ូឬទឹកក្រេស៊ីលជូតតុ-កៅអីឲ្យសព្វកន្លែង ។ មុងកំរាលពូកឬភួយ ត្រូវហាលថ្ងៃជារឿយ ៗ ហើយស្ងោរទឹកក្រេស៊ីលម្តងៗផង ។

បើលោកគ្រូមានឱកាសទៅផ្ទះសិស្ស សូមពិនិត្យមើល តើសិស្សធ្វើតាមវិធីបង្ការរោគនេះឬទេ រួចពន្យល់ឪពុក-ម្តាយសិស្សនោះឲ្យចូលចិត្តនឹងសំអាតផ្ទះសម្បែងនេះផង ។

## មេរៀនទី ២.– ទឹកនឹងសាប៊ូ

ទឹកអាចជំរះធូលីឬប្រឡាក់បេញបាន ប៉ុន្តែទឹកទទេមិនចូលល្មមនឹងជំរះមេរោគបានទេ ត្រូវយកសាប៊ូមកដុសជាមួយនឹងទឹកផងទើបអស់មន្ទិល ។ សាប៊ូគេធ្វើនឹងវត្ថុមានជាតិកាត់ជំរះមន្ទិលផ្សេងៗ គឺក្អែលឬក្រមែដែលជិតជាប់នៅលើស្បែកយើង ឬលើវត្ថុទាំងពួង ។ ដូច្នេះបូរបេះប្រើសាប៊ូ ទើបបានសេចក្តីសុខ ។

សូមលោកគ្រូនាំសិស្សទៅពាក់ងដៃ-មុខនឹងម៉ាស៊ីន បង្រៀនឱ្យវាបេះប្រើសាប៊ូ ហើយញ៉ាំងវាឱ្យចង់ប្រើសាប៊ូតទៅ ។

*មេរៀនទី ៣.–* ការថែរក្សាធ្មេញនឹងសក់

សូមមើលក្នុងសៀវភៅវិធីបង្ការរោគ មេរៀនលេខ ៩-១៥ ទំព័រ ១៥-២៣ ហើយធ្វើតាមរបៀបមុនៗ ។

---

បរិច្ចេទ ៨

## វិតស្វាផ្សាយន៍

*កាទិតៀទី ១–* អំពីការរំលាយអាហារ

ចោទសួរសិស្សឱ្យឆ្លើយរកការរំលាយអាហារ ដែលយើងខាតមិនបាននោះគឺអ្វី ។ អាហារដែលយើងបរិភោគទៅ បើមិនរលាយរលួយទៅយើងមានជីវិតឬទេ ។ នឹងបរិភោគ យើងត្រូវការអ្វីខ្លះ ។

*សេចក្តីសន្និដ្ឋាន* យើងត្រូវបរិភោគប្រយោជន៍នឹងឱ្យរស់ជីវិត ការដែលបរិភោគអាហារ ហើយរំលាយអាហារឱ្យទៅជាវត្ថុរាវជ្រាបទៅក្នុងឈាមបាននេះ ហៅថាការរំលាយអាហារ ។

កាលណាយើងបរិភោគ យើងទំពាបបារ ដ៏មានទឹកមាត់ផ្សើម អាហារទៅពីមាត់ធ្លាក់ទៅក្នុងបំពង់ក ទៅក្រពះ ទៅពោះវៀន នៅក្នុងពោះវៀនអាហារដែលរលាយស្រេចហើយនោះ ក៏បែកជាពីរបំណែកជាដើម បំណែកមួយត្រូវនៅក្នុងខ្លួន បំណែកមួយទៀតត្រូវបញ្ចេញចោលទៅក្រៅ ។

*អាទិត្យទី ២.—* ការដកដង្ហើម

សុំមើលហើយបង្រៀនតាមសៀវភៅ វិត្ថុស្វាធ្យាយន៍សំរាប់បរិប្ពណដ្ឋាន ទំព័រទី ១៤ ។

*អាទិត្យទី ៣.—* វិញ្ញាណប្រាំ កាយវិញ្ញាណ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ជីវ្ហាវិញ្ញាណនឹងឃានវិញ្ញាណ ។

សុំមើលក្នុងសៀវភៅដដែលទំព័រទី ២០-២១-២២-២៣ ២៤-២៥

*អាទិត្យទី ៤.—* ច្បាប់ដើរនូវផ្លូវ

សុំគ្រូមើលក្នុងសៀវភៅដដែលទំព័រលេខ ១០៤

## វិធីបង្ការរោគ

*អាទិត្យទី១.* អំពីភ្នែក និងការថែរក្សាភ្នែក

សុំមើលមេរៀនក្នុងសៀវភៅវិធីបង្ការរោគទំព័រលេខ ១៨

*អាទិត្យទី២* — អំពីត្របៀក និងការថែរក្សាត្របៀក

សុំមើលតាមសៀវភៅដ៏ដែលទំព័រ ២២

*អាទិត្យទី៣* — អំពីធ្មេញ និងការថែរក្សាធ្មេញ

សុំមើលតាមសៀវភៅដ៏ដែលទំព័រ ១៥

*អាទិត្យទី៤* — អំពីការថែរក្សាសក់

សុំមើលសៀវភៅដ៏ដែលទំព័រលេខ ២៣

---

## លោកនីតិ

*សម្រាប់គ្រប់ថ្នាក់*

### ១ — មេឃុំ

នៅក្នុងឃុំនិមួយ ៗ មានមន្ត្រីម្នាក់ ជាអាណាព្យាបាលលើឃុំ ដែលរាជការរដ្ឋបាលឲ្យងារជាមេឃុំ ។ មេឃុំនេះហើយដែលជាអ្នកទទួលទុក្ខសុខនិងកិច្ចការផ្សេង ៗ ពីរាស្ត្រ ហេតុនេះហើយបានជារបៀបរើសមេឃុំត្រូវរាស្ត្របំណុះឃុំរើសដោយស្ម័គ្រចិត្ត ឥឡូវនេះរបៀបតាំងមេឃុំស្រេចលើចៅហ្វាយស្រុក ជ្រើសតាំងទៅវិញ ។

របៀបនេះយើងយល់ឃើញថាពុំបានប្រសើរទេ ពីព្រោះរាស្ត្រទាំង លើមេឃុំទាំងអស់ គួរតែឲ្យរាស្ត្ររើសមេឃុំ ដូចពីដើមទើបបាន សុចរិតត្រឹមត្រូវ ។

មេឃុំមានស្មៀនម្នាក់ មានជំទប់ក្រុមជំនុំនឹងមេភូមិជួយធ្វើការ ជំទប់មាន ២ នាក់តាមធម្មតា ។

មេឃុំត្រូវទារពន្ធគ្រប់ជំពូកក្នុងឃុំ ត្រូវទទួលពាក្យបណ្ដឹងពីរាស្ត្រ ហើយផ្សះផ្សាទៀតផង បើគូសត្រូវពុំសុខចិត្តត្រូវបញ្ជូនពាក្យនោះទៅចៅហ្វាយស្រុកតាមរយៈដើម្បីឲ្យតុលាការជំនុំជំរះតាមច្បាប់

*សួរតាម* — ភូមិអ្នកនៅក្នុងឃុំណា ។ អ្នកណាត្រួតត្រាលើឃុំ ។ របៀបរើសមេឃុំដូចម្ដេចខ្លះ ពីដើមនឹងឥឡូវនេះ ។ អ្នកយល់ឃើញថារបៀបណាប្រសើរជាង ។ ពីព្រោះអ្វី ។ មុខក្រសួងមេឃុំយ៉ាងណាខ្លះ ។ល។

*មេរៀនសង្ខេប* — មេឃុំត្រួតត្រាលើឃុំទទួលទុក្ខសុខនឹងកិច្ចការផ្សេងៗពីរាស្ត្រ មានស្មៀនជំទប់ក្រុមជំនុំនឹងមេភូមិជួយទារពន្ធដារពីរាស្ត្រតាមច្បាប់បញ្ញត្តិ ។ កាលពីដើមរាស្ត្របោះឆ្នោតជ្រើសតាំងមេឃុំ ឥឡូវនេះរាជការរដ្ឋបាលសម្រេចឲ្យចៅហ្វាយស្រុកចាប់តាំងមេឃុំវិញ ។

## ២- មនុស្សបំណុះឃុំ

គ្រប់ភូមិគ្រប់ឃុំ នៃប្រទេសកម្ពុជាយើង ពុំមែនមានសុទ្ធតែជាតិខ្មែរទេ គឺមានបរជនដែរដូចចិនយួនជាដើមមានរបររកស៊ីផ្សេងពីគ្នា ប៉ុន្តែជនទាំងនេះទុកជារាស្ត្របំណុះឃុំដូចគ្នា ពីព្រោះមានទីលំនៅក្នុងរយៈឃុំនោះ ហើយបានបង់ពន្ធគ្រប់ពំពួកជូនរាជការក្នុងឃុំនោះផង ។ បណ្ដាជនក្នុងឃុំត្រូវឲ្យដឹងករណីកិច្ចរបស់ខ្លួន ។

ត្រូវជួយទំនុកបំរុងរាជការឃុំ វេលាដែលមានអាសន្នប្រតិបត្តិតាមច្បាប់បញ្ញត្តិដូចមានខាងក្រោមនេះ :

*ត្រូវបង់ពន្ធគ្រប់ពំពួកជូនមេឃុំតាមច្បាប់បញ្ញត្តិ*

ត្រូវប្ដឹងភ្នាក់ងារឃុំ កាលណាមានមនុស្សទុច្ចរិតឬមនុស្សអាក្រក់ផ្សេង ៗ ។ បើចង់ទៅនៅទីកន្លែងណាទៀត ត្រូវប្ដឹងមេឃុំឲ្យបំណាយឈ្មោះចេញពីបញ្ជីឃុំចាស់ ។

ត្រូវយកកូនទៅសុំបណ្ដុះអុតនឹងចាក់ថ្នាំការពារជម្ងឺឆ្លងផ្សេង ៗ បើកូនអាយុបាន ៦ ឆ្នាំហើយត្រូវបញ្ជូនទៅសាលារៀនកុំខាន ។

បើរើសបានវត្ថុអ្វីក្ដីឬចាប់បានសត្វពាហណៈក្ដី ដែលពុំមានម្ចាស់ ត្រូវដឹកនាំយកទៅឲ្យភ្នាក់ងារឃុំយ៉ាងឆាប់ បើមានកូនកើតឬស្លាប់ឬធ្វើបុណ្យផ្សេង ៗ ត្រូវប្ដឹងមេឃុំ ។

*សួរថា* ។– យ៉ាងដូចម្ដេចដែលហៅថាមនុស្សបំណុះឃុំ? ករណីយកិច្ចបណ្ដាជនក្នុងឃុំត្រូវធ្វើដូចម្ដេចខ្លះ ។ល។

*មោះឡែនសង្ខេប* ។– បណ្ដាជនបំណុះឃុំគឺមនុស្សប្រុសស្រីចាស់ក្មេងគ្រប់សាសន៍ដែលមានទីលំនៅ នៅក្នុងរយៈឃុំនោះ ហើយបានបង់ពន្ធដារជូនរាជការរាល់ឆ្នាំទៀតផង បណ្ដារាស្ត្រទាំងនោះត្រូវជួយទំនុកបំរុងរាជការចាំស្ដាប់បង្គាប់មេឃុំ ហើយត្រូវឲ្យដឹងករណីយកិច្ចរបស់ខ្លួនពិតប្រាកដ ទើបបានជាពលរដ្ឋដ៏ប្រសើរ ។

## ៣– អំពីស្រុក

ពាក្យស្រុកនេះប្រើបានពីរយ៉ាងៈ ១– គឺទីប្រជុំកាន់ការរាជការរដ្ឋបាលដែលនៅក្នុងអំណាចរាជការទីរួមខេត្ត ។ ២– គឺភូមិលំនៅរបស់ពួកមនុស្ស ។

នៅទីប្រជុំកាន់ការរាជការរដ្ឋបាលមានមន្ត្រីម្នាក់ អធិបតីលើទីនោះ ងារជាចៅហ្វាយស្រុក ក្នុងស្រុកនិមួយ ៗ មានឃុំច្រើន ហេតុនេះបានជារាជការ តាំងទីប្រជុំនេះនៅតំបន់ណាដែលងាយឲ្យមេឃុំបំណុះស្រុកទាំងប៉ុន្មាន ទៅមកសាលាស្រុកបានស្រួលគ្រប់ឃុំ ។

ចៅហ្វាយស្រុក មានបាឡាត់ស្រុក ឃោក្សត្រឬស្មៀននឹងប៉ូលិសជួយធ្វើការ ។

*ក្រសួងចៅហ្វាយស្រុកដូចមានខាងក្រោមនេះ*

១ ត្រូវធ្វើឲ្យរាស្ត្របានសេចក្ដីសុខ បំបាត់ចោរកំណាចចេញពីក្នុងស្រុក ដើម្បីឲ្យបានចំរើនខាងភោគសម្បត្តិ ហើយឲ្យដឹងសេចក្ដីក្រខ្សត់អត់ឃ្លាននៃបណ្ដារាស្ត្រទៀតផង ។

២– ត្រូវរៀបចំស្រុកឲ្យបានច្រើនរុងរឿង ធ្វើផ្លូវ ធ្វើស្ពាន ជីកព្រែកឲ្យចំរើនធនធាននឹងផ្លូវកាន់គ្នាទៅវិញទៅមកដល់ស្រុក ។

៣– ត្រូវប្រឹងប្រែងទំប្រមូលប្រាក់ពន្ធដារពីមេឃុំនានា ៗ យកទៅដាក់ឃ្លាំងឲ្យបានទាន់ពេលវេលា ។

៤– ត្រូវទូន្មានពន្យល់បណ្ដារាស្ត្រក្នុងស្រុកឲ្យប្រព្រឹត្តត្រឹមត្រូវ ពន្យល់អំពីរបៀបរកស៊ី អំពីវិទ្យាសាស្ត្រ ដើម្បីបំបាត់សេចក្ដីល្ងង់ខ្លៅចោលចេញ ។

*សួរថា*– ឃុំអ្នកនៅក្នុងស្រុកណា ។ យ៉ាងដូចម្ដេចដែលហៅថាស្រុក ។ នៅក្នុងស្រុកនិមួយៗ មានមន្ត្រីណាខ្លះ ។ ចៅហ្វាយស្រុកធ្វើអ្វីខ្លះ ។ល។

*មេរៀនសង្ខេប* ·– ស្រុកគឺទីប្រជុំកាន់ការរាជការរដ្ឋបាលដែលនៅក្នុងអំណាចរាជការទូវខេត្ត មានឃុំរួមមកបំណុះស្រុកជាច្រើន

ហើយមានចៅហ្វាយស្រុកជាអធិបតីលើទនោះ មានបាឡាត់ស្រុក យោកឬត្រៀននប៉ូលីស ជួយធ្វើការឲ្យបានចំរើនឲ្យបានសន្តិសុខ ដល់រាស្ត្រ ។

## អំពីខេត្ត

ខេត្តគឺទីប្រជុំស្រុក មានមន្ត្រីម្នាក់ជាន់ខ្ពស់ងារជាចៅហ្វាយខេត្តត្រួតត្រាការខុសត្រូវលើចៅហ្វាយស្រុក នឹងមន្ត្រីឯទៀតនៅក្នុងខេត្ត ។ នៅប្រទេសកម្ពុជាមាន ១៤ ខេត្ត គឺខេត្តកណ្ដាលកំពង់ស្ពឺ-តាកែវ-កំពត-ព្រៃវែង-ស្វាយរៀង-កំពង់ចាម-ក្រចេះ-ស្ទឹងត្រែង-កំពង់ធំ-កំពង់ឆ្នាំង-ពោធិ៍សាត់-សៀមរាប-បាត់ដំបង ។

*ក្រសួងចៅហ្វាយខេត្តមានភារៈក្រោមនេះ*

១ – ត្រូវប្រមូលពន្ធគ្រប់មុខពីចៅហ្វាយស្រុក ។

២ – ត្រូវរៀបចំស្រុកឲ្យបានថ្កើងរុងរឿង ឲ្យបានសន្តិសុខនឹងចំរើននូវភោគសម្បត្តិ ។

៣ – ត្រូវទទួលពត៌មានផ្សេងៗពីចៅហ្វាយស្រុក ហើយពិនិត្យមើលឲ្យបានត្រឹមត្រូវ រួចបញ្ជូនទៅតាមក្រសួង ។

៤ – ត្រូវទទួលច្បាប់បញ្ញត្តិនានាៗអំពីរដ្ឋមន្ត្រី ហើយចាត់ការបង្គាប់ទៅចៅហ្វាយស្រុកឲ្យប្រតិបត្តិតាម ។

*មេរៀនសង្ខេប* — ខេត្តជាភាគផែនដីដែលចែងជាអន្លើៗមានខណ្ឌ ដោយរដ្ឋបាលបញ្ញត្តិគឺទីប្រជុំស្រុក មានចៅហ្វាយខេត្តនាយកត្រួតត្រាការខុសត្រូវលើមន្ត្រីទាំងអស់ក្នុងខេត្ត។ចៅហ្វាយខេត្តត្រូវប្រមូលប្រាក់ពន្ធគ្រប់ជំពូកពីចៅហ្វាយស្រុក ហើយត្រូវជំនុំការផ្សេង ៗ នឹងចៅហ្វាយស្រុកនិងក្រុមប្រឹក្សាខេត្តដើម្បីរកផលប្រយោជន៍ឲ្យបំរើគ នឹងសេចក្ដីសន្តិសុខក្នុងខេត្ត កម្ពុជរដ្ឋ មាន ១៤ ខេត្តៈ កណ្ដាល, កំពង់ស្ពឺ, តាកែវ, កំពត, ព្រៃវែង, ស្វាយរៀង, កំពង់ចាម, ក្រចេះ, ស្ទឹងត្រែង, កំពង់ធំ, កំពង់ឆ្នាំង, ពោធិ៍សាត់, សៀមរាប, បាត់ដំបង។

## មេសូត្រត់មាត់

បរិវច្ឆណដ្ឋាន

### បន្ទប់រៀន

បន្ទប់រៀនខ្ញុំ មិនតូចមិនធំ ដែលខ្ញុំឃើញជាក់ ខណ្ឌដោយ
ជញ្ជាំង បាំងជាបីថ្នាក់ មួយខណ្ឌគ្រូម្នាក់ នៅបង្រៀនប្រដៅ ។ បរិ-
វច្ឆណដ្ឋាន ដែលខ្ញុំបាន រៀនបំបាត់ខ្លៅ នៅខាងស្ដាំទ្វារ
កណ្ដាលផ្ការស្មៅ មុខថ្នាក់ឥតសៅ ស្អួនផ្កាល្អណាស់ ។ ខាង
ក្រោយធ្លាធំ សម្រាប់ពួកក្រុម សិស្សវិស្សមោកាស នឹងរៀនវិជ្ជា
ហាត់ប្រាណរហ័ស ដើម្បីបានក្រាស សាច់ដុំកំលាំង ។

សព្ទពន្យល់ – ខណ្ឌ = ម. ខាន់ គឺខណ្ឌជាសង្កាត់ ជាបែកផ្តាច់ពីគ្នា ។
– គ្នារ = ផ្គរ គឺ ទីស្នូរផ្ទុះ ។
– ឆ្ការ = ភ្លឺ ។
– វិស្សមោកាស = ពាមឱកាសដែលឈប់សម្រាកកំលាំង ។
– សាច់ដុំកំលាំង = សាច់នេះកើតដោយហាត់ ទើបឡើងជាដុំ ។

## បន្ទប់រៀន (ត)

សម័យបុរាណ ម៉ែឪរាប់អាន ឲ្យកូនហាត់ខ្លាំង ខំដើរដើម្បី
បានជួយកំលាំង ប៉ុន្តែកម្សាំង បាត់ផ្ទរប្រៀនបុត្រ ។ ព្រោះយល់
ថាមនុស្ស យើងនេះស្រីប្រុស កើតឡើងមកសុទ្ធ តែខ្លាំងខ្លួនឯង
យ៉ាងនេះបំហុត ទោះខ្សោយវិញផុត នៅជាតិកំណើត ។ គំនិត
នេះខុស បើតាមធម៌ព្រះ ប្រាកដជាពិត ជឿថាបាបបុណ្យ បាន
សាងឲ្យកើត ឲ្យកកំណើត តាមកម្មខ្លួនធ្វើ ។ បើគិតឲ្យត្រូវ
សម័យឥឡូវ ផ្លូវរៀនសារពើ ប្រយោជន៍យ៉ាងធំ ពុំគិតអំពើ តែ
ធ្វេសមិនធ្វើ គឺគ្មានគេរាប់ ។

សព្ទពន្យល់ – កម្សាំងបាត់ = គំនិតដែលគិតមិនឃើញ ដូចជាពន្លឺថ្ងៃល្ងាចដែល
កម្សាំងលិចបាត់នឹងចុងព្រៃ ឬកំពូលភ្នំ ។
– ប្រៀនបុត្រ = ហ្វឹកហាត់កូន ឲ្យចេះចំណេះនានា ។
– បំហុត = ដែលត្រូវ ដែលពិត ដែលប្រាកដ ។
– ធម៌ព្រះ = ធម៌ព្រះពុទ្ធ រមែងពោលថា បើធ្វើបុណ្យ បានអានិសង្ស
ឲ្យកើតកំលាំងគ្រប់យ៉ាង; បើធ្វើបាប ផលកម្មបាប ឲ្យខ្សោយគ្រប់យ៉ាង

អានិកាដ្ឋានទីដមធ្យមដ្ឋានទី ១

## ក្រុងភ្នំពេញ

មានក្រុងតិចណាស់ ដែលរៀបរហ័ស ហើយបានប្ដុំប្ដើង ជាទីក្រុងធំ ដូចភ្នំពេញយើង ដែលកកើតឡើង លើផែនដីខ្មែរ ។ ហាក់ផុសចេញពី ព្រះធរណី ឡើងមកប្នោះដែរ ឬទេពនិម្មិត ដោយឫទ្ធិបំបែរ បំបែកស្រុកខ្មែរ កុំឲ្យខ្មាស់គេ ។ ពីដើមស្មៅដុះ ស្ទួញស្មាញកុញ្ញកុះ កំប៉ុតព្រៃទេ ដីទៀតផ្ហុក ត្រពាំងប្លុកគេ ទុកចោលទទេលែងគោក្របី ។ ឲ្យដើរស៊ីស្មៅ កណ្ដាលវាលក្ដៅ ឥតប្រយោជន៍អ្វី ឯសព្វថ្ងៃនេះ ផ្ទះថ្មបាស់ថ្មី ព័ទ្ធពាសពេញដី ហូរហែរក្បៀថ្នល់ ។ ផ្លូវត្រឡែងកែង ចាក់ជ័រផ្លូវវែង ដីលែងហុយដល់លើទីលំនៅ រជួរព្រុះខ្យល់ នេះហើយត្រូវស្គាល់ ជាក្រុងរុងរឿង ។

---

សព្ទពន្យល់ — ព្រះធរណី=ម.ឋ. ព្រះធរនី ដី ។ ទេពនិម្មិត=ដែលទេវតានិម្មិត ។
— ឫទ្ធិ = សេចក្ដីសម្រេច; អំណាចរុងរឿង សេចក្ដីចំរើន ។ —
ផ្លូវត្រឡែងកែង = ផ្លូវបែកជា ៤ ។

## ក្រុងភ្នំពេញ (ត)

យើងហៅផ្សារធំ ចាស់នោះសមរម្យ ជាការដំកើង ណាស់ដែរតែរើ រុះធ្វើថ្មីឡើង មួនមាំប្ដុំប្ដើង គួរឲ្យអស្ចារ្យ ។ អស់ជន

គ្រប់ជាតិ ត្រាច់ដើរគគាត ឈ្មួញពេញផ្សារ ខ្លះប្តូរខ្លះបេញ ទិញស្បៀងអាហារ ឬមួយត្រូវការ របស់ផ្សេងៗ ។ សិនបាន ដូចចិត្ត នេះពោលតាមពិត គិតបុះក្មេងៗ គឺគ្មានក្រុងណា គគ្រឹកគគ្រេង ជាងភ្នំពេញលេង ទេកុំសង្ស័យ ។ នេះគឺភ័ព្វបុណ្យ ប្រជាជាតិជន បំណុះក្រុងក្រៃ ឲ្យឃើញនឹងភ្នែក ប្លែកៗរាល់ថ្ងៃ បែបសុរិល័យ សម័យឥឡូវ ។

---

សព្ទពន្យល់ – ត្រាច់ដើរគគាត = កិ.វិ. ឬគុ. អង់អាច, ឥតក្រែង, ឥតភ្លឹក
– ដើរឥតភ្លឹក ឈ្មួញ = កិ.វិ. មនុស្សដើរឈ្មួញ ។
– គគ្រឹកគគ្រេង = កិ.វិ. ឬគុ. ពាក្យសំរាប់ចំរើន ការផ្សេងៗ
– ឲ្យប្លែកឡើង ។
– ភ័ព្វបុណ្យ ឬ បុណ្យភ័ព្វ = បុណ្យសំណាង ។

---

## មជ្ឈដ្ឋានទី ២ ជនឧត្តមដ្ឋាន

## បណ្ដាជនក្នុងសហរដ្ឋឥណ្ឌូចិន

ជាតិគ្មានកំណត់ ក្នុងសហរដ្ឋ ឥណ្ឌូចិននេះ សឹងមានច្រើន សាសន៍ កុំបីសន្ទេះ តែក្នុងទីនេះ សង្ខេបយ៉ាងខ្លី ។ នឹងពោលចំ-ពោះ សាសន៍ខ្មែរប៉ុណ្ណោះ ដែលនៅបុរី រដ្ឋមណ្ឌល មានទាំងប្រុស ស្រី ដេរដាសពាសដី ក្រុងកម្ពុជា ។ ក្រៅពីជាតិខ្មែរ មានជាតិ

ម្លួយវៃរ ហៅថាជាតិផ្ង នៅតាមអាត់ប្រាំង ជ្រោយមេគង្គ ហើយ សង់គ្រឹះហោ រៀងគ្នាហ្វូរហែ ។ ជំពូកជនម្លូករ ហៅថាជាតិគួយ ព្នងផងសំរ៉ែ ហើយរាប់តរៀង ទោស្ទៀងរដែ ជាតិនេះនៅតែ ដោយព្រៃដោយផ្សៃ ។ ខ្លះនៅដោយភ្នំ ស៊ីសត្វតូចធំ ជាអចិន្ត្រៃយ លើកតែដំរី គេមិនអាស្រ័យ ទាក់ទុកសំបែ ជាពាហនៈ ។

---

សព្ទពន្យល់ — រដ្ឋៈមណ្ឌល = មណ្ឌលរបស់ដែន, ប្រទេសទាំងមូល ។

— មេគង្គ = មេក្នុងឈ្មោះមហានទី គឺទន្លេធំ ។

— គ្រឹះហោ = ផ្ទះសំបែង ។

— ពាហនៈ = គ្រឿងប្រើប្រាស់សម្រាប់ជិះ, សម្រាប់ដឹកនាំ ។

— អចិន្ត្រៃយ = និរន្តរ អលដ្ឋិ ជានិច្ច សព្វកាល រាល់ថ្ងៃ ។

## បណ្តាជនក្នុងសហរដ្ឋឥណ្ឌូចិន (ត)

ប៉ែកពួកជ្វាចាម សឹងសាសនាឥស្លាម មកគ្រប់តែផ្ទះ ប្បាប់ម៉ុហ៍មម៉ាត់ បតិបត្តិសំពះ ជាសរណៈ ទីពឹងយ៉ាងធំ ។ បញ្ចិមជីវិត ដោយសុចរិត មធ្យ័តមធ្យម តែងបាប់មច្ឆា នានទីធំ ស្ត្រីបាមនិយម ការត្បាញរវៃ ។ ក្មេងគិតរវល់ ម៉ែឪពន្យល់ ប្រយោជន៍ប្រពៃ ឲ្យរៀនរាល់គ្នា ក្នុងវិទ្យាល័យ ដែលនៅក្នុងថ្មើ នៃប្រជុំជន ។ ក៏បានបំណោះ ពេញជាអ្នកបេះ តាមស្រាលតាមធ្ងន់ តាមតិចតាមច្រើន ដោយសារអត់ធន់ បំពោះជាជន អ្នកបេះដឹងដែរ ។ (ប.ត.)

សព្ទពន្យល់ – ឥស្លាម្មិក = សាសនាម្ហាសសួតិរបស់ជាមផ្កា ហៅថាអារ៉ោះកា-ទៀក៏មាន ។
– ម៉ូហ៉ាំមម៉ាត់ = ពាក្យអារ៉ាប់ ឬមហាហ្មុត នាមរបស់សាស្តាម្នាក់ កើតនៅក្រុងម៉េក្កៈ ជាមេលទ្ធិបង្កើតសាសនាអ៊ីស្លាម ឬឥស្លាម្មិក ។
– នទីធំ = ស្ទឹងធំ, ទន្លេធំ ឬមេគង្គ ។

## រឿងមើលកុំសាគ្គ

*ធាខនិកណ្ណុរបាស់*

សូមសាធកៈ កាព្យាភិរៈ នេះនាំនិទាន តាមរឿងបារាំង តាំងជាប្រធាន ប្រៀបធៀបទន្សាន តមកជាអារ៍ ។ ថាមានសត្វឆ្មា ឈ្មោលមួយឬស្សា មហាឧបាទ៍រិ គំនិតកោងកាច កំណាចហេសខ្លាត ល្បីល្បាញផ្ទៀវឆ្លាត ឈ្លបចាប់កណ្តុល ។ ឈ្មោះរ៉ូឌីឡារ "Rodilard" មហិទ្ធិការ ហាក់អង្គអសុល គ័ង្គមាសូរ សិរិទសពល បញ្ញាប្រគល់ ការត្រួតនរក ។ (នៅមានត)

សព្ទពន្យល – សាធកៈ = ខ្មែរច្រើនប្រើជាកិ. ឬ គុ. ថា នាំមកសំដែង; អធិប្បាយពន្យល់ ។
– ភិរៈនេះ = វេលានេះ ។
– មហាឧបាទ៍រ = ពាក្យប្រើក្លាយមកពីម. (ឧបទ្ទវ) ឧបទ្រព ចង្រៃ
– អសុល = អសុរ យករជាលម. ថ. អសុល ។
– គ័ង្គមាសូរ = ឈ្មោះយក្សមួយ មានក្នុងរឿងរាមកេរ្តិ៍ ។
– សិរ = មើលថា សិរៈ ន. ព្រះឥសូរ ។